# អង្គុលិមាលសូត្រ ទី៦ (បិដក២៤ ទំព័រ៤៣២)

## (បិដក អដ្ឋកថា ដីកា)



រៀបរៀងដោយភិក្ខុ នួន សារ៉េត ព.ស២៥៦៦, គ.ស២០២៣

# *សេចក្ដីផ្ដើម*

*សៀវភៅនេះ ខ្ញុំព្រះករុណា អាត្មាភាព ភិក្ខុ សារត្ថធម្មោ នួន សារ៉េត បាន រៀបរៀងឡើង ដើម្បីជាប្រយោជន៍ដល់ពុទ្ធបរិស័ទទូទៅ បានការសិក្សាស្រាវជ្រាវ និង បដិបត្តិក្នុងព្រះធម៌របស់ព្រះសម្មាសម្ពុទ្ធ ដើម្បីជាប្រយោជន៍ ដល់សង្គមជាតិ សាសនា របស់ខ្មែរយើង នឹងជួយជាចំណេះដឹង ដល់កុលបុត្រ កុលធីតា ប្អូនៗ បងៗ ជា និស្សិត ក្នុងសៀវភៅនេះផងដែរ ។*

*ពិតណាស់ សង្គមមួយ ដែលមានមនុស្សចេះដឹងច្រើន យល់ដឹងច្រើន នឹង ឈានទៅរកការអភិវឌ្ឍបានរីកចម្រើន ភាពសម្បូរសប្បាយ លូតលាស់ ជឿនលឿន ប្រកបដោយសុខចម្រើន ក្នុងសង្គមនោះពុំខាន ។ ហេតុនេះហើយ ខ្ញុំព្រះករុណា អាត្មាភាព នឹងសង្ឃឹមថា សៀវភៅនេះ នឹងបានជាយោជន៍ដល់ជនច្រើន ។*

*សេចក្ដីរៀបរាប់មកខាងលើនេះ សូមជូនពរ ឲ្យពុទ្ធបរិស័ទទាំងអស់ និង ប្អូនៗ បងៗ សិក្សា បដិបត្តិ ឲ្យបានជាប្រយោជន៍ ជាចំណេះដឹង ជាមេរៀន ជាមេគំនិត សម្រាប់ដំណើរជីវិតនេះ ប្រកបតែសេចក្ដីសុខ សេចក្ដីចម្រើន និង រួចចាកទុក្ខទាំងពួង កុំបីអាក់ខានឡើយ ។*

*សូមថ្វាយព្រះរាជកុសលនេះ ដល់ព្រះមហាក្សត្រាក្សត្រីខ្មែរគ្រប់ជំនាន់ និងថ្វាយ ព្រះរាជកុសលដល់ព្រះសង្ឃរាជទាំងទាំងពីរគណៈគ្រប់ជំនាន់ និងមន្ត្រីសង្ឃគ្រប់រូប ព្រមទាំងបុព្វបុរសវីរៈជនខ្មែរគ្រប់រូប ពុទ្ធបរិស័ទទាំងអស់ សូមអនុមោទនានូវធម្មទាន ដែលខ្ញុំព្រះករុណា អាត្មាភាព បានបំពេញនេះ ហើយសូមឲ្យតែបានសេចក្ដីសុខ សេចក្ដីចម្រើន និងរួចចាកទុក្ខទាំងពួងកុំបីអាក់ខានឡើយ ។*

*វត្តស្រះមុជ្ជលិន្ទ ថ្ងៃទី២០ ខែមេសាឆ្នាំ២០២៣*

សារត្ថធម្មោ នួន សារ៉េត

## អង្គុលិមាលសូត្រ ទី៦ (បិដក២៤ ទំព័រ៤៣២)

[២៨២] ខ្ញុំបានស្តាប់មកយ៉ាងនេះ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់សម្រេចព្រះឥរិយាបថ ក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី។ សម័យនោះឯង ក្នុងដែនព្រះបាទបសេនទិកោសល មានចោរម្នាក់ឈ្មោះ អង្គុលិមាល ជាមនុស្សកាច មានដៃប្រឡាក់ឈាម ស្ទិទ្ធក្នុងការបៀតបៀននឹងការសម្លាប់ ឥតមានសេចក្តីអាណិតអាសូរពួកសត្វមានជីវិតឡើយ។ ចោរនោះ តែងធ្វើស្រុកឲ្យទៅជាមិនមែនស្រុកក៏មាន ធ្វើនិគមឲ្យទៅជាមិនមែននិគមក៏មាន ធ្វើជនបទ ឲ្យទៅជាមិនមែនជនបទក៏មាន។ ចោរនោះ តែងសម្លាប់ពួកមនុស្ស ហើយកាត់យកម្រាមដៃ មកធ្វើជាកម្រងពាក់។ គ្រានោះ ព្រះមានព្រះភាគ ទ្រង់ស្បង់ ប្រដាប់បាត្រ និងចីវរ ក្នុងបុព្វណ្ហសម័យ ទើបស្តេចចូលទៅកាន់ក្រុងសាវត្ថី ដើម្បីបិណ្ឌបាត លុះចូលទៅបិណ្ឌបាតក្នុងក្រុងសាវត្ថី ហើយត្រឡប់ពីបិណ្ឌបាត ក្នុងកាលជាខាងក្រោយនៃភត្ត ទ្រង់ក៏រៀបចំសេនាសនៈ រួចប្រដាប់បាត្រ និងចីវរ ស្តេចទៅកាន់ផ្លូវឆ្ងាយសំដៅទៅត្រង់ទី ដែលអង្គុលិមាលចោរនៅ។ ពួកអ្នកឃ្វាលគោ អ្នកឃ្វាលបសុសត្វ [ពួកសត្វដែលគេចិញ្ចឹម។] អ្នកភ្ជួររាស់ និងអ្នកដើរផ្លូវ បានឃើញព្រះមានបុណ្យ កំពុងស្តេចទៅកាន់ផ្លូវឆ្ងាយ សំដៅទៅត្រង់ទី ដែលអង្គុលិមាលចោរនៅ លុះឃើញហើយ ក៏ក្រាបទូលព្រះមានបុណ្យដូច្នេះថា បពិត្រព្រះសមណៈ សូមព្រះអង្គ កុំនិមន្តទៅកាន់ផ្លូវនុ៎ះឡើយ បពិត្រព្រះសមណៈ ដ្បិតក្នុងផ្លូវនុ៎ះ មានចោរឈ្មោះ អង្គុលិមាល ជាមនុស្សកាច មានដៃប្រឡាក់ឈាម ស្ទិទ្ធក្នុងការបៀតបៀន និងការសម្លាប់ ឥតមានសេចក្តីអាណិតអាសូរពួកសត្វមានជីវិតឡើយ ចោរនោះ តែងធ្វើស្រុក ឲ្យទៅជាមិនមែនស្រុកក៏មាន ធ្វើនិគម ឲ្យទៅជាមិនមែននិគមក៏មាន ធ្វើជនបទ ឲ្យទៅជាមិនមែនជនបទក៏មាន ចោរនោះ តែងសម្លាប់ពួកមនុស្ស ហើយកាត់យកម្រាមដៃ មកធ្វើជាកម្រងពាក់ បពិត្រព្រះសមណៈ ព្រោះបុរស១០នាក់ក្តី ២០នាក់ក្តី ៣០នាក់ក្តី ៤០នាក់ក្តី នាំគ្នាដើរជាពួកៗ ទៅកាន់ផ្លូវនុ៎ះ ក៏បុរសទាំងនោះឯង ដល់នូវសេចក្តីវិនាស ក្នុងកណ្តាប់ដៃ នៃអង្គុលិមាលចោរ (ទាំងអស់)។ កាលបើពួកមនុស្សក្រាបទូលយ៉ាងនេះ ព្រះមានបុណ្យ ក៏ទ្រង់ស្ងៀម ទ្រង់ចេះតែស្តេចទៅ។

[២៨៣] ពួកអ្នកឃ្វាលគោ អ្នកឃ្វាលបសុសត្វ អ្នកភ្ជួររាស់ និងអ្នកដើរផ្លូវ ក្រាបទូលព្រះមានបុណ្យ ជាគំរប់ពីរដង ដូច្នេះថា បពិត្រព្រះសមណៈ សូមព្រះអង្គ កុំនិមន្តទៅកាន់ផ្លូវនុ៎ះឡើយ បពិត្រព្រះសមណៈ ដ្បិតក្នុងផ្លូវនុ៎ះ មានចោរឈ្មោះអង្គុលិមាល ជាមនុស្សកាច មានដៃប្រឡាក់ឈាម ស្ទិទ្ធក្នុងការបៀតបៀន និងការសម្លាប់ ឥតមានសេចក្តីអាណិតអាសូរពួកសត្វមានជីវិតឡើយ ចោរនោះ តែងធ្វើស្រុក ឲ្យទៅជាមិនមែនស្រុកក៏មាន ធ្វើនិគម ឲ្យទៅជាមិនមែននិគមក៏មាន ធ្វើជនបទ

ឲ្យទៅជាមិនមែនជនបទក៏មាន ចោរនោះ តែងសម្លាប់ពួកមនុស្ស កាត់យកម្រាមដៃ មកធ្វើជាកម្រងពាក់ បពិត្រព្រះសមណៈ ព្រោះបុរស១០នាក់ក្តី ២០នាក់ក្តី ៣០នាក់ក្តី ៤០នាក់ក្តី នាំគ្នាដើរជាពួកៗ ទៅកាន់ផ្លូវនុ៎ះ ក៏បុរសទាំងនោះឯង ដល់នូវសេចក្តីវិនាស ក្នុងកណ្តាប់ដៃ នៃអង្គុលិមាលចោរ (ទាំងអស់)។ លំដាប់នោះឯង ព្រះមានបុណ្យ ក៏ទ្រង់ស្ងៀម ទ្រង់ចេះតែស្តេចទៅ។

[២៨៤] ពួកអ្នកឃ្វាលគោ អ្នកឃ្វាលបសុសត្វ អ្នកភ្ជួររាស់ និងអ្នកដើរផ្លូវ ក្រាបទូលព្រះមានបុណ្យ ជាគំរប់៣ដងទៀត ដូច្នេះថា បពិត្រព្រះសមណៈ សូមព្រះអង្គ កុំនិមន្តទៅកាន់ផ្លូវនុ៎ះឡើយ បពិត្រព្រះសមណៈ ដ្បិតក្នុងផ្លូវនុ៎ះ មានចោរឈ្មោះ អង្គុលិមាល ជាមនុស្សកាច មានដៃប្រឡាក់ឈាម ស្និទ្ធក្នុងការបៀតបៀន និងការសម្លាប់ ឥតមានសេចក្តីអាណិតអាសូរពួកសត្វមានជីវិតឡើយ ចោរនោះ តែងធ្វើស្រុក ឲ្យទៅជាមិនមែនស្រុកក៏មាន ធ្វើនិគម ឲ្យទៅជាមិនមែននិគមក៏មាន ធ្វើជនបទ ឲ្យទៅជាមិនមែនជនបទក៏មាន ចោរនោះ តែងសម្លាប់ពួកមនុស្ស កាត់យកម្រាមដៃ មកធ្វើជាកម្រងពាក់ បពិត្រព្រះសមណៈ ព្រោះបុរស១០នាក់ក្តី ២០នាក់ក្តី ៣០នាក់ក្តី ៤០នាក់ក្តី នាំគ្នាដើរជាពួកៗ ទៅកាន់ផ្លូវនុ៎ះ ក៏បុរសទាំងនោះឯង ដល់នូវសេចក្តីវិនាស ក្នុងកណ្តាប់ដៃ នៃអង្គុលិមាលចោរ (ទាំងអស់)។ គ្រានោះឯង ព្រះមានបុណ្យ ក៏ទ្រង់ស្ងៀម ទ្រង់ចេះតែស្តេចទៅ។

[២៨៥] ឯអង្គុលិមាលចោរ ក៏បានឃើញព្រះមានបុណ្យ កំពុងតែស្តេចមកអំពីចម្ងាយ។ លុះឃើញហើយ ក៏ត្រិះរិះ ដូច្នេះថា យីអើ អស្ចារ្យណាស់ អើហ្ន៎ ចំឡែកណាស់ ព្រោះបុរស១០នាក់ក្តី ២០នាក់ក្តី ៣០នាក់ក្តី ៤០នាក់ក្តី នាំគ្នាដើរជាពួកៗ មកកាន់ផ្លូវនេះ ក៏បុរសទាំងនោះឯង ដល់នូវសេចក្តីវិនាស ក្នុងកណ្តាប់ដៃរបស់អញ (ទាំងអស់) ចុះសមណៈនេះ តែម្នាក់ឯង ឥតមានគ្នាសោះ ក៏ហ៊ានដើរមក ហាក់ដូចជាមិនកោតញញើតឡើយ បើដូច្នោះ អញនឹងសម្លាប់សមណៈនេះ ឲ្យក្ស័យជីវិត។ គ្រានោះ អង្គុលិមាលចោរ ក៏ចាប់ដាវ និងខែល សៀតធ្នូ និងបំពង់ព្រួញ ដេញព្រះមានព្រះភាគជាប់តាមក្រោយ។ លំដាប់នោះ ព្រះមានព្រះភាគ ទ្រង់សំដែងឫទ្ធិ ធ្វើឲ្យអង្គុលិមាលចោរ ដែលរត់ពេញទំហឹងហើយ មិនឲ្យរត់តាមទាន់ព្រះអង្គ ដែលស្តេចដើរតាមដំណើរប្រក្រតី។ គ្រានោះ អង្គុលិមាលចោរ មានសេចក្តីត្រិះរិះ ដូច្នេះថា យីអើ អស្ចារ្យណាស់ យីអើ ចំឡែកណាស់ ព្រោះកាលពីមុនៗមក អញស្ទុះដេញចាប់ដំរីកំពុងបោលក៏បាន ស្ទុះដេញចាប់សេះកំពុងផាយក៏បាន ស្ទុះដេញចាប់រថកំពុងលឿនក៏បាន ស្ទុះដេញចាប់ម្រឹគកំពុងបោលក៏បាន ចំឡែកតែម្តងនេះ ហេតុអ្វីបានជាអញរត់ពេញទំហឹងហើយ ក៏នៅតែមិនទាន់សមណៈនេះ ដែលដើរតាមដំណើរប្រក្រតីដូច្នេះ។ អង្គុលិមាលចោរ ឈប់ឈរស្ងៀម ស្រែកឃាត់ព្រះមានបុណ្យថា ឈប់សិនសមណៈ ឈប់

សិនសមណៈ។ ព្រះមានបុណ្យ ត្រាស់តបថា នែអង្គុលិមាល តថាគតឈប់ហើយ អ្នកឯងចូរឈប់ដែរទៅ។

[២៨៦] គ្រានោះ អង្គុលិមាលចោរ គិតថា ពួកសមណៈនេះ ជាសក្យបុត្រ ធ្លាប់និយាយតែពាក្យពិត ប្តេជ្ញាតែពាក្យពិត ចំឡែកតែសមណៈនេះ កំពុងដើរទេ ម្តេចឡើយក៏និយាយថា នែអង្គុលិមាល តថាគតឈប់ហើយ អ្នកចូរឈប់ដែរទៅ បើដូច្នោះ អញត្រូវសួរសមណៈនេះមើល។ លំដាប់នោះ អង្គុលិមាលចោរ ក៏ពោលនឹងព្រះមានព្រះភាគ ដោយគាថា ដូច្នេះថា

នែសមណៈ លោកកំពុងដើរសោះទេ ត្រឡប់និយាយថា តថាគតឈប់ហើយ ថែមទាំងថាឲ្យខ្ញុំដែលឈប់ហើយថា អ្នកឯងទេ មិនទាន់ឈប់ដូច្នេះវិញ នែសមណៈ ខ្ញុំសូមសួរដំណើរនុ៎ះនឹងលោក លោកដែលឈប់ហើយ តើដូចម្តេច ខ្ញុំដែលមិនទាន់ឈប់ តើដូចម្តេច។ ព្រះអង្គតបថា នែអង្គុលិមាល តថាគត បានឈ្មោះថា ឈប់ហើយ (នោះ) ព្រោះដាក់ចុះ នូវគ្រឿងវាយដំ ចំពោះពួកសត្វទាំងក្នុងអដ្ឋកថា លោកពន្យល់ថា ព្រះអង្គទ្រង់ទំលាក់នូវគ្រឿងវាយដំសត្វចោលចេញហើយ ប្រព្រឹត្តក្នុងធម៌៥យ៉ាងគឺ មេត្តា១ ខន្តី១ បដិសង្ខា (ការពិចារណា)១ អវិហឹសា១ សារាណីយធម៌១ បានជាព្រះអង្គប្រាប់អង្គុលិមាលថា តថាគតឈប់ហើយ គឺឈប់ធ្វើអំពើអាក្រក់។] អស់ សព្វៗកាល ឯអ្នកឯង ជាអ្នកមិនសង្រួម ក្នុងពួកសត្វ ព្រោះហេតុនោះ តថាគត ទើបឈ្មោះថា ជាអ្នកឈប់ហើយ អ្នកឯងឈ្មោះថា ជាអ្នកមិនទាន់ឈប់។ អង្គុលិមាលចោរ តបថា នែសមណៈ លោកស្វែងរកនូវគុណដ៏ធំ ជាអ្នកដែលទេវតា និងមនុស្ស តែងបូជា លោកមកកាន់មហាវ័ន (ដើម្បីសង្គ្រោះ) ដល់ខ្ញុំអស់កាលយូរហើយ ខ្លួនខ្ញុំនឹងប្រព្រឹត្តតាម នឹងលះបង់នូវបាបចោលចេញ ព្រោះបានស្តាប់នូវគាថា របស់ព្រះអង្គ ដែលប្រកបដោយធម៌ (ចោរ) ថាដូច្នេះហើយ ក៏គ្រវែងដាវ និងអាវុធចោលទៅក្នុងត្រពាំងក្នុងជ្រោះ ក្នុងរណ្តៅ អង្គុលិមាលចោរ ក៏ថ្វាយបង្គំព្រះបាទា នៃព្រះសុគត ហើយសូមផ្នួសនឹងព្រះអង្គ ក្នុងទីនោះឯង។ ចំណែកព្រះពុទ្ធ ព្រះអង្គប្រកបដោយករុណា ទ្រង់ស្វែងរកនូវគុណដ៏ធំ ដែលជាគ្រូ នៃមនុស្សលោក ព្រមទាំងទេវលោក បានត្រាស់ហៅអង្គុលិមាលចោរនោះថា អ្នកចូរមកជាភិក្ខុចុះ ដូច្នេះ ក្នុងគ្រានោះ ភិក្ខុភាពនោះឯង ក៏កើតមាន ដល់អង្គុលិមាលចោរនោះ។

គ្រានោះ ព្រះភគវន្តមុនី ទ្រង់យកអង្គុលិមាលភិក្ខុមានអាយុ ជាបច្ឆាសមណៈ ស្តេចធ្វើពុទ្ធដំណើរ សំដៅទៅក្រុងសាវត្ថី។ ព្រះអង្គ កាលស្តេចចារិកតាមលំដាប់ ក៏បានដល់ទៅក្រុងសាវត្ថីនោះ។

[២៨៧] ដំណាលថា ព្រះភគវន្តមុនី ព្រះអង្គគង់នៅក្នុងជេតវនារាម របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី។ គាប់ចួនសម័យនោះ ពួកមហាជន កំពុងតែប្រជុំគ្នា ទៀបទ្វារខាងក្នុងបុរី របស់ព្រះបាទបសេនទិកោសល ស្រែកហ៊ោគឹកកងថា បពិត្រព្រះសម្មតិទេព ក្នុងដែនរបស់ព្រះអង្គ មានចោរឈ្មោះអង្គុលិមាល ជាមនុស្សកាច មានដៃប្រឡាក់ឈាម ស្ទិទ្ធក្នុងការបៀតបៀន និងការសម្លាប់ ឥតមានសេចក្ដីអាណិតអាសូរពួកសត្វមានជីវិតឡើយ វាតែងធ្វើស្រុក ឲ្យទៅជាមិនមែនស្រុកក៏មាន ធ្វើនិគមឲ្យទៅជាមិនមែននិគមក៏មាន ធ្វើជនបទ ឲ្យទៅជាមិនមែនជនបទក៏មាន វាតែងសម្លាប់ពួកមនុស្ស ហើយកាត់យកម្រាមដៃ មកធ្វើជាកម្រងពាក់ សូមព្រះសម្មតិទេព កំចាត់អង្គុលិមាលចោរនោះចេញ។ លំដាប់នោះ ព្រះបាទបសេនទិកោសល ស្ដេចចេញអំពីក្រុងសាវត្ថី ដោយអស្សយានចំនួន៥០០ ស្ដេចចូលទៅកាន់អារាម ក្នុងវេលាទាំងថ្ងៃ បរយានទៅទល់ត្រឹមទីដែលឈប់យាន ហើយស្ដេចចុះអំពីយាន ស្ដេចទៅតែព្រះបាទាទទេ ចូលសំដៅទៅរកព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំព្រះមានព្រះភាគហើយ គង់ក្នុងទីដ៏សមគួរ។

[២៨៨] លុះព្រះបាទបសេនទិកោសល គង់ក្នុងទីដ៏សមគួរហើយ ព្រះមានបុណ្យ ទ្រង់ត្រាស់សួរថា បពិត្រមហារាជ ទំនងជាមហាបពិត្រ ខ្ញាល់នឹងព្រះបាទមគធសេនិយពិម្ពិសារ ឬខ្ញាល់នឹងស្ដេចលិច្ឆវី អ្នកក្រុងវេសាលី ឬក៏ខ្ញាល់នឹងពួកស្ដេច ដែលជាបច្ចាមិត្រឯទៀត ឬអ្វី។ ព្រះបាទបសេនទិកោសល ក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គ មិនខឹងនឹងព្រះបាទមគធសេនិយពិម្ពិសារ មិនខឹងនឹងស្ដេចលិច្ឆវី អ្នកក្រុងវេសាលី មិនខឹងនឹងពួកស្ដេច ដែលជាបច្ចាមិត្រឯទៀតទេ បពិត្រព្រះអង្គដ៏ចំរើន ក្នុងដែនរបស់ខ្ញុំព្រះអង្គ មានចោរឈ្មោះអង្គុលិមាល ជាមនុស្សកាច មានដៃប្រឡាក់ឈាម ស្ទិទ្ធក្នុងការបៀតបៀន និងការសម្លាប់ ឥតមានសេចក្ដីអាណិតអាសូរពួកសត្វមានជីវិតឡើយ វាតែងធ្វើស្រុកឲ្យទៅជាមិនមែនស្រុកក៏មាន ធ្វើនិគមឲ្យទៅជាមិនមែននិគមក៏មាន ធ្វើជនបទ ឲ្យទៅជាមិនមែនជនបទក៏មាន វាតែងសម្លាប់ពួកមនុស្ស កាត់យកម្រាមដៃ មកធ្វើជាកម្រងពាក់ បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គ នឹងកំចាត់អង្គុលិមាលចោរនោះចេញ។ ព្រះមានបុណ្យត្រាស់ថា បពិត្រមហារាជ ចុះបើមហាបពិត្រ ត្រឡប់ជាឃើញអង្គុលិមាល កោរសក់ ពុកមាត់ និងពុកចង្កា ស្លៀកដណ្ដប់សំពត់កាសាយៈ ចេញចាកផ្ទះ ទៅកាន់ផ្នួស វៀរចាកបាណាតិបាត វៀរចាកអទិន្នាទាន វៀរចាកមុសាវាទ បរិភោគភត្តតែមួយពេល ប្រព្រឹត្តធម៌ដ៏ប្រសើរ មានសីល មានធម៌ដ៏ល្អវិញ តើមហាបពិត្រ ត្រូវធ្វើអង្គុលិមាលនោះ ដូចម្ដេចទៅ។ ព្រះបាទបសេនទិកោសល ក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គ គប្បីថ្វាយបង្គំ ឬក្រោកទៅទទួល និមន្តដោយអាសនៈ ឬទំនុកបំរុង

នូវអង្គុលិមាលនោះ ដោយចីវរ បិណ្ឌបាត សេនាសនៈ ថ្នាំរក្សារោគ ជាបច្ច័យដល់អ្នកជម្ងឺ និងបរិក្ខារទាំងឡាយ ឬនឹងចាត់ចែងនូវការរក្សា សេចក្តីការពារ និងការគ្រប់គ្រង ប្រកបដោយធម៌ ដល់អង្គុលិមាលនោះ បពិត្រព្រះអង្គដ៏ចំរើន បើអង្គុលិមាលចោរនោះ ធ្លាប់ជាមនុស្សទ្រុស្តសីល មានធម៌ដ៏លាមកហើយ ធ្វើម្តេចនឹងសង្រួមក្នុងសីលយ៉ាងនោះកើត។

[២៨៩] ចួនសម័យនោះឯង អង្គុលិមាលភិក្ខុមានអាយុ កំពុងអង្គុយជិតព្រះមានព្រះភាគ។ គ្រានោះ ព្រះមានព្រះភាគ លើកព្រះហស្តខាងស្តាំ ចង្អុលបង្ហាញព្រះបាទបសេនទិកោសលថា បពិត្រមហារាជ នុ៎ះហ្ន៎ អង្គុលិមាល។ លំដាប់នោះ ព្រះបាទបសេនទិកោសល ក៏មានសេចក្តីភ័យភិត តក់ស្លុត ព្រឺរោម ព្រឺស្បែកឡើងមួយរំពេច។ គ្រានោះ ព្រះមានព្រះភាគ ជ្រាបជាក់ថា ព្រះបាទបសេនទិកោសល ទ្រង់ភ័យញ័រចំប្រប់ ព្រឺរោម ដូច្នោះហើយ ក៏ត្រាស់ទៅនឹងព្រះបាទបសេនទិកោសល ដូច្នេះថា បពិត្រមហារាជ សូមមហាបពិត្រ កុំភ័យឡើយ បពិត្រមហារាជ សូមមហាបពិត្រកុំភ័យឡើយ ភ័យអំពីសំណាក់អង្គុលិមាលនេះ មិនមានដល់មហាបពិត្រទេ។ លំដាប់នោះ ភ័យណាក្តី សេចក្តីតក់ស្លុតណាក្តី សេចក្តីព្រឺរោម ព្រឺស្បែកណាក្តី បានកើតមានដល់ព្រះបាទបសេនទិកោសល ភ័យជាដើមនោះ ក៏ស្ងប់រម្ងាប់បាត់ទៅ ក្នុងលំដាប់នោះឯង។ គ្រានោះ ព្រះបាទបសេនទិកោសល ក៏ចូលទៅជិតអង្គុលិមាលភិក្ខុមានអាយុ លុះចូលទៅដល់ហើយ ក៏មានព្រះឱង្ការ សួរអង្គុលិមាលភិក្ខុមានអាយុ ដូច្នេះថា បពិត្រព្រះអង្គដ៏ចំរើន លោកម្ចាស់ឈ្មោះអង្គុលិមាលឬ។ អង្គុលិមាលមានអាយុ តបថា ថ្វាយព្រះពរមហារាជ។ ព្រះបាទបសេនទិកោសល មានព្រះបន្ទូលសួរថា បពិត្រលោកម្ចាស់ដ៏ចំរើន ចុះបិតាលោកម្ចាស់គោត្រអ្វី មាតាលោកម្ចាស់គោត្រអ្វី។ អង្គុលិមាលមានអាយុ តបថា ថ្វាយព្រះពរមហារាជ បិតា (អាត្មាភាព) ជាគគ្គគោត្រ មាតា (អាត្មាភាព) ជាមន្តានីគោត្រ។ ព្រះបាទបសេនទិកោសល មានព្រះរាជឱង្ការបវារណាថា បពិត្រលោកម្ចាស់ដ៏ចំរើន សូមលោកម្ចាស់គគ្គគោត្រ មន្តានីបុត្រ អភិរម្យចុះ ខ្ញុំព្រះករុណា នឹងទំនុកបំរុងដោយចីវរ បិណ្ឌបាត សេនាសនៈ ថ្នាំរក្សារោគ ជាបច្ច័យដល់អ្នកជម្ងឺ និងបរិក្ខារទាំងឡាយ ដល់លោកម្ចាស់ គគ្គគោត្រ មន្តានីបុត្រ។ សម័យនោះឯង  អង្គុលិមាលមានអាយុ ប្រព្រឹត្តនៅតែក្នុងព្រៃ ប្រព្រឹត្តតែបិណ្ឌបាត ប្រើប្រាស់តែសំពត់បង្សុកូល ប្រើប្រាស់តែចីវរ៣។ បានជាកាលនោះ អង្គុលិមាលភិក្ខុមានអាយុ ថ្វាយព្រះពរព្រះបាទបសេនទិកោសលថា ពុំបាច់ទេមហារាជ អាត្មាភាព មានត្រៃចីវរគ្រប់គ្រាន់ហើយ។

[២៩០] លំដាប់នោះ ព្រះបាទបសេនទិកោសល ស្តេចចូលទៅគាល់ព្រះមានព្រះភាគ លុះស្តេចចូលទៅដល់ហើយ ក៏ថ្វាយបង្គំព្រះមានព្រះភាគ ហើយគង់ក្នុងទីដ៏សមគួរ។ លុះព្រះបាទប

សេនទិកោសល គង់ក្នុងទីដ៏សមគួរហើយ ក៏ក្រាបទូលសេចក្តីនេះ នឹងព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចំរើន អស្ចារ្យណាស់ បពិត្រព្រះអង្គដ៏ចំរើន ចំឡែកណាស់ បពិត្រព្រះអង្គដ៏ចំរើន ព្រោះថាព្រះមានព្រះភាគ ព្រះអង្គ អាចទូន្មានបុរស ដែលគេទូន្មានមិនបាន អាចរម្ងាប់បុរស ដែលគេរម្ងាប់មិនបាន អាចរំលត់ពុតត្បុតបុរស ដែលគេរំលត់មិនបាន បពិត្រព្រះអង្គដ៏ចំរើន ដ្បិតខ្ញុំព្រះអង្គ មិនអាចនឹងទូន្មាននូវបុរសណា ដោយអាជ្ញាក្តី ដោយគ្រឿងសស្ត្រាវុធក្តី ព្រះមានព្រះភាគ អាចទូន្មានបុរសនោះបាន ដោយមិនបាច់មានអាជ្ញា ដោយមិនបាច់មានគ្រឿងសស្ត្រាវុធ បពិត្រព្រះអង្គដ៏ចំរើន ក៏ឥឡូវនេះ ខ្ញុំព្រះអង្គ សូមថ្វាយបង្គំលាទៅវិញ ព្រោះខ្ញុំព្រះអង្គ មានកិច្ចការច្រើន មានការរវល់ច្រើន។ ព្រះអង្គត្រាស់ថា ថ្វាយព្រះពរមហារាជ សូមមហាបពិត្រ ទ្រង់ជ្រាបនូវកាលដ៏គួរនឹងស្តេចយាងទៅ ក្នុងកាលឥឡូវនេះចុះ។ គ្រានោះ ព្រះបាទបសេនទិកោសល ក៏ក្រោកចាកអាសនៈ ហើយក្រាបថ្វាយបង្គំលាព្រះមានព្រះភាគហើយ ធ្វើប្រទក្សិណ ស្តេចចេញទៅ។

[២៩១] លំដាប់នោះ អង្គុលិមាលមានអាយុ ស្លៀកស្បង់ ប្រដាប់បាត្រ ចីវរ ក្នុងបុព្វណ្ហសម័យ រួចចូលទៅកាន់ក្រុងសាវត្ថី ដើម្បីបិណ្ឌបាត។ អង្គុលិមាលមានអាយុ កាលទៅតាមលំដាប់ច្រក ដើម្បីបិណ្ឌបាត ក្នុងក្រុងសាវត្ថី បានចួបនឹងស្ត្រីម្នាក់ វង្វេងស្មារតី ព្រោះគភ៌ មិនសប្បាយព្រោះគភ៌ [ឈឺពោះ សម្រាលកូន។]។ លុះលោកឃើញហើយ ក៏គិតថា អើហ្ន៎ ពួកសត្វលំបាកណាស់ អើហ្ន៎ ពួកសត្វលំបាកណាស់។ លំដាប់នោះ អង្គុលិមាលមានអាយុ ទៅបិណ្ឌបាតក្នុងក្រុងសាវត្ថី លុះត្រឡប់ពីបិណ្ឌបាត ក្នុងកាលជាខាងក្រោយ នៃភត្តហើយ ក៏ឆៀងចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំព្រះមានព្រះភាគ រួចអង្គុយក្នុងទីដ៏សមគួរ។ លុះអង្គុលិមាលមានអាយុ អង្គុយក្នុងទីដ៏សមគួរហើយ ក៏ក្រាបទូលដំណើរនុ៎ះ ចំពោះព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គបានស្លៀកស្បង់ ប្រដាប់បាត្រ ចីវរ ក្នុងបុព្វណ្ហសម័យ ក្នុងទីឯណោះ រួចចូលទៅកាន់ក្រុងសាវត្ថី ដើម្បីបិណ្ឌបាត បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គ កំពុងដើរទៅតាមលំដាប់ច្រក ដើម្បីបិណ្ឌបាត ក្នុងក្រុងសាវត្ថី បានចួបនឹងស្ត្រីម្នាក់វង្វេងស្មារតី ព្រោះគភ៌ មិនសប្បាយព្រោះគភ៌ លុះខ្ញុំព្រះអង្គឃើញហើយ ក៏គិតថា អើហ្ន៎ ពួកសត្វលំបាកណាស់ អើហ្ន៎ ពួកសត្វលំបាកណាស់។

[២៩២] ព្រះអង្គត្រាស់ថា ម្នាលភិក្ខុអង្គុលិមាល បើដូច្នោះ ចូរអ្នកចូលទៅរកស្ត្រីនោះ លុះចូលទៅដល់ហើយ ចូរនិយាយនឹងស្ត្រីនោះ យ៉ាងនេះថា នែនាង តាំងអំពីអាត្មាកើតមក មិនដែលក្លែងផ្តាច់ផ្តិលជីវិតសត្វឡើយ ដោយពាក្យសច្ចៈនេះ សូមសិរីសួស្តី កើតមានដល់នាង សូមសិរីសួស្តីកើតមានដល់គភ៌។ អង្គុលិមាល ទូលថា បពិត្រព្រះអង្គដ៏ចំរើន សម្បជានមុសាវាទ នឹងមានដល់ខ្ញុំ

ព្រះអង្គដោយពិត បពិត្រព្រះអង្គដ៏ចំរើន ព្រោះខ្ញុំព្រះអង្គ បានក្លែងផ្តាច់ផ្តិលជីវិតសត្វជាច្រើន។ ព្រះអង្គត្រាស់ថា ម្នាលអង្គុលិមាល បើដូច្នោះ ចូរអ្នកចូលទៅរកស្រ្តីនោះ លុះចូលទៅដល់ហើយ ចូរនិយាយនឹងស្រ្តីនោះ យ៉ាងនេះថា នែនាង តាំងអំពីអាត្មាកើតហើយ ក្នុងអរិយជាតិ (បានជាអរិយបុគ្គល) មិនដែលក្លែងផ្តាច់ផ្តិលជីវិតសត្វឡើយ ដោយពាក្យសច្ចៈនេះ សូមសិរីសួស្តី កើតមានដល់នាង សូមសិរីសួស្តី កើតមានដល់គភ៌។ អង្គុលិមាលមានអាយុ ទទួលព្រះពុទ្ធដីកាព្រះមានបុណ្យថា ករុណាព្រះអង្គ ហើយក៏ចូលទៅរកស្រ្តីនោះ លុះចូលទៅដល់ហើយ ក៏និយាយនឹងស្រ្តីនោះ ដូច្នេះថា

**“យតោហំ, ភគិនិ, អរិយាយ ជាតិយា ជាតោ, នាភិជានាមិ សញ្ចិច្ច បាណំ ជីវិតា វោរោបេតា, តេន សច្ចេន សោត្ថិ តេ ហោតុ, សោត្ថិ គព្ភស្សា”តិ។**

នែនាង តាំងអំពីអាត្មាកើតហើយ ក្នុងអរិយជាតិ មិនដែលក្លែងផ្តាច់ផ្តិលជីវិតសត្វឡើយ ដោយពាក្យសច្ចៈនេះ សូមសិរីសួស្តី កើតមានដល់នាង សូមសិរីសួស្តី កើតមានដល់គភ៌។

គ្រានោះឯង សិរីសួស្តី ក៏បានកើតដល់ស្រ្តីនោះ សិរីសួស្តី ក៏បានកើតដល់គភ៌។

[២៩៣] លំដាប់នោះ អង្គុលិមាលមានអាយុ ជាបុគ្គលម្នាក់ឯង ដោះខ្លួនចេញចាកពួក ឥតមានសេចក្តីធ្វេសប្រហែស មានព្យាយាម ដុតនូវកិលេស ប្រថុយលះបង់នូវអត្តភាព ពួកកុលបុត្រដែលចេញចាកផ្ទះហើយ ចូលទៅកាន់ផ្នួសដោយប្រពៃ ដើម្បីប្រយោជន៍ ដល់អនុត្តរធម៌ណា មិនយូរប៉ុន្មាន លោកក៏បានធ្វើឲ្យជាក់ច្បាស់ នូវអនុត្តរធម៌នោះ ដែលជាទីបំផុត នៃព្រហ្មចរិយៈ ដោយប្រាជ្ញារបស់ខ្លួន ដោយខ្លួនឯង ក្នុងបច្ចុប្បន្ននេះ ហើយសម្រេចសម្រាន្តនៅ ដោយឥរិយាបថទាំង៤ ក៏បានដឹងច្បាស់ថា ជាតិកំណើតរបស់អញ អស់ហើយ មគ្គព្រហ្មចរិយធម៌ អាត្មាអញ បានប្រព្រឹត្តរួចហើយ សោឡសកិច្ច អាត្មាអញ បានធ្វើរួចហើយ មគ្គភាវនាកិច្ចដទៃ ក្រៅពីសោឡសកិច្ចនេះទៀត មិនមានឡើយ។ បណ្តាព្រះអរហន្តទាំងឡាយ អង្គុលិមាលមានអាយុ រាប់ថាជាព្រះអរហន្តមួយរូបដែរ។

[២៩៤] លំដាប់នោះ អង្គុលិមាលមានអាយុ ស្លៀកស្បង់ ប្រដាប់បាត្រ ចីវរ ក្នុងបុព្វណ្ហសម័យ ហើយចូលទៅ ដើម្បីបិណ្ឌបាត ក្នុងក្រុងសាវត្ថី។ សម័យនោះឯង មនុស្សដទៃ យកដុំដីគ្រវែងចោល ធ្លាក់ទៅលើកាយអង្គុលិមាល មានអាយុក៏មាន មនុស្សដទៃយកដំបងគ្រវែងចោលធ្លាក់ទៅលើកាយអង្គុលិមាលមានអាយុក៏មាន មនុស្សដទៃ យកក្រួសផ្ទាត់ធ្លាក់ទៅលើកាយអង្គុលិមាលមានអាយុក៏មាន។ គ្រានោះ អង្គុលិមាលមានអាយុ (មានរបួស) បែកសីសៈ ហូរឈាម បែក

បាត្រ រហែកសង្ឃាដិ ក៏ដើរចូលទៅគាល់ព្រះមានបុណ្យ។ ព្រះមានបុណ្យ បានទតឃើញអង្គុលិមាលមានអាយុ កំពុងដើរមកអំពីចម្ងាយ លុះឃើញហើយ ក៏ត្រាស់ទូន្មានអង្គុលិមាលមានអាយុ ដូច្នេះថា ព្រាហ្មណ៍ ចូរអ្នកខំអត់ទ្រាំទៅ ព្រាហ្មណ៍ ចូរអ្នកខំអត់ធ្មត់ទៅ អ្នកគួរនឹងឆេះ ក្នុងនរកជាច្រើនឆ្នាំ ជាច្រើនរយឆ្នាំ ជាច្រើនពាន់ឆ្នាំ ដោយវិបាកនៃកម្មណា ម្នាលព្រាហ្មណ៍ អ្នកបានទទួលរងវិបាក នៃកម្មនោះ ក្នុងបច្ចុប្បន្ននេះ (តែប៉ុណ្ណោះ)ទេ។

[២៩៥] វេលានោះ អង្គុលិមាលមានអាយុ ទៅនៅក្នុងទីរហោស្ថាន ពួនសម្ងំតែម្នាក់ឯង បានប្រទះនូវវិមុត្តិសុខ ទើបបន្លឺឧទាននេះ ក្នុងវេលានោះថា

បុគ្គលណា ធ្វេសប្រហែសក្នុងកាលមុន ដល់កាលជាខាងក្រោយមក បុគ្គលនោះ មិនធ្វេសប្រហែសវិញ បុគ្គលនោះ ឈ្មោះថា ញុំាំងលោក [ពាក្យថា លោក១ ក្នុងទីនេះ សំដៅយកខន្ធ ធាតុ អាយតនៈរបស់ខ្លួន។ អដ្ឋកថា។] នេះ ឲ្យភ្លឺច្បាស់ ដូចព្រះចន្ទ្រ ផុតស្រឡះចាកពពក បាបកម្ម ដែលបុគ្គលណាធ្វើហើយ តែបុគ្គលនោះ ត្រឡប់ជាបិទបាន គឺមិនទទួលផលកម្មវិញ ដោយសារកុសល គឺមគ្គ បុគ្គលនោះ ឈ្មោះថា ញុំាំងលោកនេះឲ្យភ្លឺច្បាស់ ដូចព្រះចន្ទ្រ ផុតស្រឡះចាកពពក ភិក្ខុណា កំឡោះនៅឡើយ ប្រកបព្យាយាម ក្នុងព្រះពុទ្ធសាសនា ភិក្ខុនោះឯង ឈ្មោះថា ញុំាំងលោកនេះឲ្យភ្លឺច្បាស់ ដូចព្រះចន្ទ្រ ផុតស្រឡះចាកពពក សូមពួកមនុស្សជាសត្រូវ ស្តាប់ធម្មកថារបស់ខ្ញុំ សូមពួកមនុស្សជាសត្រូវនឹងខ្ញុំ ប្រកបព្យាយាមក្នុងពុទ្ធសាសនា ពួកសប្បុរសណា តែងដឹកនាំមនុស្សឲ្យរៀនធម៌ សូមពួកមនុស្សជាសត្រូវនឹងខ្ញុំ សេពគប់ពួកសប្បុរសទាំងនោះចុះ សូមពួកមនុស្សជាសត្រូវនឹងខ្ញុំ ស្តាប់ធម៌ជាទីផ្សរផង់ គឺខន្តិ ទាំងជាទីសរសើរ នូវការមិនខឹង គឺមេត្តា តាមកាលដ៏សមគួរផង សូមពួកមនុស្សជាសត្រូវនឹងខ្ញុំ បំពេញនូវធម៌នោះផង មនុស្សណាជាសត្រូវនឹងខ្ញុំ សូមសត្រូវនោះកុំបៀតបៀនខ្ញុំ ទាំងកុំបៀតបៀនបុគ្គលដទៃណាមួយឡើយ សូមឲ្យដល់នូវសេចក្តីសុខ គឺព្រះនិព្វាន ចូររក្សានូវមនុស្ស ដែលប្រកបដោយតណ្ហា និងមនុស្សដែលមិនមានតណ្ហា។ ពួកអ្នកបង្ហូរទឹក រមែងបង្ហូរទឹក (តាមប្រឡាយទឹក) ពួកអ្នកធ្វើកូនសរ រមែងពត់កូនសរ ពួកអ្នកចាំងឈើ រមែងចាំងឈើ អ្នកប្រាជ្ញទាំងឡាយ រមែងទូន្មានខ្លួនបានដូច្នោះដែរ។ ពួកមនុស្សខ្លះ ទូន្មានដោយដម្បង ដោយកង្វេរ ដោយរំពាត់ ចំណែកខ្ញុំជាអ្នកមានអាជ្ញា ដែលព្រះមានបុណ្យ ជាតាទិបុគ្គល មិនបានយកដម្បង ឬគ្រឿងសស្ត្រាវុធ (មកទូន្មានខ្ញុំទេ) កាលដើមខ្ញុំឈ្មោះថា អហឹសកកុមារ (ជាអ្នកមិនបៀតបៀនគេ) តែជាអ្នកបៀតបៀនគេ ដល់មកថ្ងៃនេះ ខ្ញុំមានឈ្មោះទៀងទាត់ គឺសមតាមឈ្មោះដើមខ្ញុំហើយ ព្រោះខ្ញុំមិនបៀតបៀនអ្នកណាមួយទៀតទេ កាលពីដើម ខ្ញុំជាចោរ មាននាមប្រាកដថា

អង្គុលិមាល ដែលជំនន់ធំបន្សាត់ទៅ (តែឥឡូវនេះ) ខ្ញុំបានដល់នូវព្រះពុទ្ធ ជាទីពឹងហើយ កាលពីដើម ខ្ញុំមានដៃប្រឡាក់ឈាម មាននាមប្រាកដថា អង្គុលិមាល (តែឥឡូវនេះ) សរណគមន៍ ខ្ញុំបានដល់ហើយ តណ្ហាជាគ្រឿងនាំទៅកាន់ភព ខ្ញុំបានគាស់រំលើងចោលហើយ ខ្ញុំបានធ្វើអំពើដែលគួរទៅកាន់ទុគ្គតិ ដូច្នោះ ច្រើនពិតមែន តែកម្មវិបាក គឺមគ្គចេតនា បានមកអប់រំ (ក្នុងសន្តានខ្ញុំហើយ) ខ្ញុំជាអ្នកលែងចំពាក់បំណុល គឺកិលេស បរិភោគភោជន ពួកជនពាល ឥតប្រាជ្ញា តែងប្រកបសេចក្តីប្រមាទ ឯអ្នកប្រាជ្ញតែងរក្សាសេចក្តីមិនប្រមាទទុក ដូចរក្សាទ្រព្យ ដ៏ថ្លៃថ្លា សូមអ្នកទាំងឡាយ កុំប្រកបសេចក្តីប្រមាទឡើយ កុំប្រកបសេចក្តីត្រេកអរ នឹងការមូលមិត្រក្នុងកាមឡើយ ព្រោះថាបុគ្គលអ្នកមិនប្រហែសធ្វេស ខំដុតបំផ្លាញ (នូវកិលេស) រមែងបានដល់នូវសេចក្តីសុខដ៏ទូលាយ ខ្ញុំមកល្អហើយ ខ្ញុំមិនគេចចេញទេ គំនិតនេះ ខ្ញុំមិនមែនគិតខុសទេ បណ្តាធម៌ទាំងឡាយ ដែលព្រះអង្គចែករលែកល្អហើយ ព្រះនិព្វានណា ជាគុណជាតិ ដ៏ប្រសើរ ខ្ញុំបានដល់ នូវព្រះនិព្វាននោះហើយ ខ្ញុំមកល្អហើយ ខ្ញុំមិនគេចចេញទេ គំនិតនេះ ខ្ញុំមិនមែនគិតខុសទេ វិជ្ជា៣ប្រការ ខ្ញុំបានសម្រេចហើយ ពុទ្ធសាសនា ខ្ញុំបានធ្វើតាមហើយ។

ចប់ អង្គុលិមាលសូត្រ ទី៦ (ក្នុងបិដក)

# អ ដ្ឋ ក ថា

## អង្គុលិមាលសូត្រទី ៦

[២៨២] *អង្គុលិមាលសូត្រ មានពាក្យចាប់ផ្ដើមថា ខ្ញុំបានស្ដាប់មក យ៉ាងនេះ ៖*

*សួរថា ក្នុងព្រះសូត្រនោះ ពាក្យថា ទ្រទ្រង់កម្រងនៃម្រាមដៃ ទ្រទ្រង់ទុក ព្រោះហេតុអ្វី ។ ឆ្លើយថា ទ្រទ្រង់ទុកតាមពាក្យរបស់អាចារ្យ ។ ក្នុងសេចក្ដីនោះ មានអនុបុព្វកថា ដូចតទៅនេះ ៖*

*បានឮថា ព្រះអង្គុលិមាលនេះ បានបដិសន្ធិក្នុងគភ៌នៃនាងព្រាហ្មណី ឈ្មោះ* **មន្តានី** *នៃបុរោហិតរបស់ព្រះបាទកោសល ។ នាងព្រាហ្មណីបានប្រសូតបុត្រក្នុងវេលាពេលយប់ ។ ក្នុងវេលាដែលអង្គុលិមាលនោះប្រសូតចាកគភ៌មាតា អាវុធទាំងឡាយក្នុងនគរទាំងអស់ភ្លឺឆ្វាលឡើង ។ សូម្បីពន្លឺដែលជាមង្គលរបស់ព្រះរាជា សូម្បីទាំងស្រោមដាវដែលនៅក្នុងក្រឡា-បន្ទំដ៏សិរីក៏រុងរឿង ។ ព្រាហ្មណ៍ទើបក្រោកចេញមក ហើយមើលផ្កាយនក្សត្រ ក៏ដឹងថា បុត្រកើតដោយនក្សត្រចោរ ទើបចូលគាល់ព្រះរាជា ទូល*

សួរដល់ការផ្ទំជាសុខ ។

ព្រះរាជាត្រាស់ថា លោកអាចារ្យ យើងមិនដេកជាសុខទៅបានពីណា បើអាវុធដែលជាមង្គលរបស់យើងភ្លឺរុងរឿង ឃើញថាមិនមានអន្តរាយដល់រដ្ឋ ឬដល់ជីវិត ។ បុរោហិតទូលថា បពិត្រមហារាជ ទ្រង់កុំខ្លាចឡើយ កុមារកើតហើយក្នុងផ្ទះរបស់ទូលបង្គំ អាវុធទាំងឡាយ មិនមែនមិនរុងរឿង ដោយអានុភាពរបស់កុមារនោះ ។ មិនមានហេតុអ្វី លោកអាចារ្យ ។ បពិត្រព្រះមហារាជ គេមិនជាចោរ ។ គេមិនជាចោរម្នាក់ ឬថា មិនជាចោរប្រទូស-រ៉ាយដល់រាជសម្បត្តិ ។ គេមិនជាចោរធម្មតាម្នាក់មិនធ្វើអ្វីបាន ។ ឯបុរោ-ហិតកាលក្រាបទូលយ៉ាងនោះហើយ ដើម្បីមិនយកព្រះទ័យរបស់ព្រះរាជា ទើបទូលថា ចូរសម្លាប់វាចុះព្រះអង្គ ។ ព្រះរាជា ។ ជាចោរធម្មតាមិនធ្វើអ្វីបាន ។ ដូចស្រូវសាលីតែមួយគុម្ពក្នុងស្រែទាំងពាន់ករីសៈ ចូរទំនុកបម្រុងគេទុកចុះ ។ កាលមិនតាំងឈ្មោះកុមារនោះ វត្ថុទាំងនេះ គឺ ស្រោមដាវដែលជាមង្គលដែលដាក់ទុកក្នុងទីក្រឡាបន្ទំ កូនសរដែលដាក់ទុកក្នុងបំពង់ កូនកាំបិតសម្រាប់កាត់ទងត្នោតដែលទុកក្នុងសំឡីកប្បាស ឆេះឡើងបញ្ចេញពន្លឺតែមិនបៀតបៀន ដូច្នោះ ទើបតាំងឈ្មោះថា **អហិង្សកៈ** ។ លុះវេលា

នឹងឲ្យរៀនសិល្បៈ ក៏បញ្ជូនគេទៅកាន់ក្រុងតក្កសិលា ។ អហិង្សកកុមារនោះ ជាធម្មន្តេវាសិក ផ្តើមរៀនសិល្បៈហើយ ។ ជាអ្នកដល់ព្រមដោយវត្ត តាំងចិត្តបម្រើប្រព្រឹត្តជាទីពេញចិត្ត និយាយចរចាពីរោះ ។ ចំណែកអន្តេ-វាសិកដ៏សេស ជាអន្តេវាសិកខាងក្រៅ ។ អន្តេវាសិកទាំងនោះ អង្គុយប្រឹក្សាគ្នាថា ចាប់តាំងពីវេលាដែលអហិង្សកមាណពមក ពួកយើងមិនប្រាកដឡើយ យើងនឹងទម្លាយគេបានយ៉ាងណា នឹងនិយាយថា ជាអ្នកល្ងង់ក៏និយាយមិនបាន ព្រោះមានបញ្ញាក្រៃលែងជាងពួកយើង នឹងថា មានវត្តមិនល្អ ក៏មិនអាចនិយាយ ព្រោះជាអ្នកសម្បូរណ៍ដោយវត្ត នឹងថា មានជាតិថោកទាប ក៏និយាយមិនបាន ព្រោះសម្បូរណ៍ដោយជាតិ ពួកយើងនឹងធ្វើយ៉ាងណា ខណៈនោះ ប្រឹក្សានឹងអ្នកមានឆ្លាតវាងវៃម្នាក់ថា យើងនឹងធ្វើចន្លោះរបស់អាចារ្យទម្លាយគេចេញ បែងចែកជាបីពួក ពួកដំបូងចូលទៅរកអាចារ្យ សំពះហើយឈរ ។ អាចារ្យសួរថា អ្វីបា ។ ក៏ប្រាប់ថា ពួកខ្ញុំបានស្តាប់រឿងមួយក្នុងផ្ទះនេះ ។ កាលអាចារ្យសួរថា អ្វីបា ។ ក៏ពោលថា ពួកយើងជ្រាបថា អហិង្សកមាណពនឹងប្រទូសរ៉ាយជាមួយលោកអាចារ្យ ។ អាចារ្យទើបគំហកដេញចេញថា ចេញទៅ អ្នកឯងថោកទាប អ្នកឯងកុំទម្លាយបុត្ររបស់យើង

ក្នុងពីយើងចេញឡើយ ។ បន្ទាប់ពីនោះ ក៏ទៅមួយពួកទៀត គង់ពីនោះ ក៏ទៅមួយពួកទៀត ទាំងបីពួក បានពោលទំនងតែមួយដូចគ្នា ហើយក៏ពោលថា បើអាចារ្យមិនជឿពួកខ្ញុំ ក៏ចូរដើរដោយខ្លួនឯងចុះ ដូច្នេះ ។ លោកអាចារ្យឃើញសិស្សទាំងឡាយ ពោលដោយសេចក្តីហួនហែង ទើបសម្រេចចិត្តថា នឹងមានសេចក្តីពិត ទើបគិតថា យើងនឹងសម្លាប់វា ។

គទៅទើបគិតទៀតថា បើយើងសម្លាប់វា នរណាៗ ដែលគិតថា លោកអាចារ្យទិសាបាមោក្ខ ញ៉ាំងទោសឲ្យកើតឡើងក្នុងមាណពអ្នកមករៀនសិល្បៈក្នុងសម្នាក់របស់ខ្លួន ហើយផ្តាច់ជីវិតចេញ ដូច្នេះ ក៏មិនមកដើម្បីរៀនសូត្រសិល្បៈទៀត ដោយអាការយ៉ាងនេះ យើងក៏នឹងសាបសូន្យលាភ កុំដូច្នោះឡើយ យើងនឹងប្រាប់វាថា នៅមានសិល្បៈវិជ្ជាថ្នាក់ចុងក្រោយបង្អស់ ហើយពោលថា អ្នកឯងត្រូវសម្លាប់មនុស្សឲ្យបានមួយពាន់នាក់ ក្នុងរឿងនេះ ឯងនឹងជាបុគ្គលម្នាក់លេចធ្លោឡើង សម្លាប់មនុស្សឲ្យបានគ្រប់មួយពាន់ ។ ពេលនោះ អាចារ្យទើបពោលចំពោះអហិង្សកកុមារថា មកចុះបា អ្នកចូរសម្លាប់មនុស្សឲ្យបានមួយពាន់នាក់ កាលធ្វើបានដូច្នេះ ក៏នឹងជាការធ្វើឧបចារៈដល់សិល្បៈ ការបូជាគ្រូ ដូច្នេះ ។ អហិង្សកកុមារ ទើបពោលថា បពិត្រ

លោកអាចារ្យ ខ្ញុំកើតក្នុងត្រកូលដែលមិនបៀតបៀន ខ្ញុំមិនអាចធ្វើដូច្នោះ ។ សិល្បៈដែលមិនបានតម្លៃបូជាគ្រូ ក៏នឹងមិនឲ្យផលនោះទេ ។ អហិង្សកកុមារ ទើបកាន់យកអាវុធ ៥ ប្រការ សំពះអាចារ្យចូលកាន់ព្រៃ ឈរក្នុងទីដែលមនុស្សនឹងចូលទៅកាន់ព្រៃខ្លះ ត្រង់កណ្តាលព្រៃខ្លះ ត្រង់ទីដែលអ្នកចេញពីព្រៃខ្លះ សម្លាប់មនុស្សអស់ជាច្រើន ។ ក៏មិនកាន់យកសំពត់ ឬសំពត់ផ្ទត់សីសៈ ធ្វើត្រឹមតែកំណត់ថា ១ ឬ២ ដូច្នេះ ដើរទៅ សូម្បីការរាប់ ក៏កំណត់មិនបាន ។ តែដោយធម្មតា អហិង្សកកុមារនេះ ជាអ្នកមានបញ្ញា តែចិត្តមិនតាំងមាំបាន ព្រោះបាណាតិបាត ។ ដូច្នោះ ទើបកំណត់សូម្បីការរាប់មិនបានតាមលំដាប់ ។ គេកាត់ម្រាមដៃបានមួយៗ ក៏រក្សាទុក ។ ក្នុងទីដែលរក្សាទុក ម្រាមដៃក៏វិនាសអស់ទៅ ។ តអំពីនោះ ទើបក្រងធ្វើជាកម្រងម្រាមដៃពាក់ ។ ដោយហេតុនោះឯង គេទើបប្រាកដឈ្មោះថា **អង្គុលិមាល** ។ អង្គុលិមាលនោះ ត្រាច់ទៅកាន់ព្រៃទាំងអស់ ដរាបមិនមានអ្នកណាអាចទៅព្រៃដើម្បីរកឧសជាដើម ។ ក្នុងពេលយប់ក៏ចូលមកកាន់ខាងក្នុងស្រុក យកជើងធាក់ទ្វារ ។ តពីនោះ ក៏សម្លាប់មនុស្សដែលដេកនោះឯង កំណត់ថា ១ , ១ ដើរទៅ ។ ស្រុកក៏បង្ហឹតថយទៅតាំងក្នុងនិគម ។ និគមក៏បង្ហឹត

ថយទៅតាំងនៅក្នុងក្រុង ។ ពួកមនុស្សលះបង់ស្រុក នាំកូនធ្វើដំណើរមក លោមព័ទ្ធព្រះនគរសាវត្ថី អស់រយៈផ្លូវដែលបីយោជន៍ តាំងបន្ទាយសម្រាក ប្រជុំគ្នាត្រង់កជកំង មនុស្សជាច្រើនពោលរៀបរាប់ផ្សេងៗ គ្នាថា បពិត្រសម្មតិទេព ក្នុងព្រំដែនរបស់ព្រះអង្គ មានចោរឈ្មោះអង្គុលិមាលជាដើម ។ ក្នុងលំដាប់នោះ ព្រាហ្មណ៍ក៏ដឹងថា ចោរអង្គុលិមាលនោះ គឺជាបុត្ររបស់ខ្លួន ទើបពោលទៅនឹងនាងព្រាហ្មណីថា នែនាងដ៏ចម្រើន កើតចោរឈ្មោះអង្គុ-លិមាលឡើងហើយ ចោរនោះមិនមែនអ្នកដទៃណា គឺ អហិង្សកកុមារជាកូនរបស់នាង ឥឡូវនេះ ព្រះរាជាស្តេចនឹងចេញទៅចាប់គេ យើងគួរនឹងធ្វើយ៉ាងណា ។ នាងព្រាហ្មណីនិយាយថា លោកទៅចុះ ចូរទៅនាំកូនរបស់យើងមក ។ ព្រាហ្មណ៍និយាយថា នែនាងដ៏ចម្រើន ខ្ញុំមិនអាចទៅ ព្រោះមិនទុកចិត្តដល់បុគ្គល ៤ ពួក គឺ ចោរដែលជាសម្លាញ់ចាស់របស់យើង មិនគួរធ្វើទុកក្នុងចិត្តដល់សម្លាញ់ដែលធ្លាប់មានសន្ថវមេត្រីនឹងគ្នាមកពីមុន ព្រះរាជាក៏មិនគួរទុកចិត្តថា នឹងរាប់អានយើង ។ ស្ត្រីក៏មិនគួរទុកចិត្តថា រាប់នៅក្នុងសាច់ញាតិរបស់យើង តែចិត្តរបស់ម្តាយ មានចិត្តទន់ ដូច្នោះ នាងព្រាហ្មណីទើបពោលថា ខ្ញុំនឹងទៅនាំកូនរបស់ខ្ញុំមក ដូច្នេះ ទើបចេញ

ទៅ ។ នឹងក្នុងថ្ងៃនោះ ព្រះមានព្រះភាគទ្រង់ពិចារណាមើលសត្វលោកក្នុងវេលាបច្ចូសម័យជិតភ្លឺ ទ្រង់ឃើញអង្គុលិមាល ទើបទ្រង់ព្រះតម្រិះថា កាលតថាគតទៅ នឹងជាសេចក្តីសួស្តីដល់គេ អ្នកដែលនៅក្នុងព្រៃ ដែលគេស្រុកមិនបាន កាលបានស្តាប់គាថាដែលប្រកបដោយបទ ៤ បទ ចេញបួសក្នុងសម្នាក់របស់តថាគតហើយ នឹងធ្វើឲ្យច្បាស់នូវអភិញ្ញា ៦ បើតថាគតមិនទៅ គេនឹងធ្វើខុសក្នុងមាតា នឹងជាអ្នកដែលនរណាៗ លើកឡើងមិនបាន តថាគតនឹងធ្វើការសង្គ្រោះគេ ដូច្នេះ ហើយទ្រង់ស្លៀកដណ្តប់ក្នុងវេលាព្រឹក ចូលទៅដើម្បីបិណ្ឌបាត ទ្រង់ធ្វើភត្តកិច្ចស្រេចហើយ បំណងនឹងសង្គ្រោះគេ ទើបស្តេចចេញចាកពីវិហារ ។ ដើម្បីនឹងសម្តែងសេចក្តីនេះ លោកទើបពោលថា **អថ ខោ ភគវា** ដូច្នេះជាដើម ។ ពាក្យថា **សន្ធិតេ្វា សន្ធិតេ្វា** សេចក្តីថា ជាពួកៗ ធ្លាប់សង្កេត ។ បទថា **ហត្ថត្ថំ គច្ឆន្តិ** សេចក្តីថា ដល់ការតាំងនៅមិនបានក្នុងដៃ គឺ វិនាសទៅ ។ សួរថា ក៏អ្នកទាំងនោះចាំព្រះមានព្រះភាគបាន ដូចម្តេចពោលយ៉ាងនេះថា ចាំមិនបានឬ ? ឆ្លើយថា ចាំមិនបាន ។ ព្រោះព្រះមានព្រះភាគក្លែងភេទ ស្តេចទៅត្រឹមតែមួយព្រះអង្គឯង ។

ក្នុងសម័យនោះ សូម្បីចោរក៏សោប់សោល់ក្នុងចិត្ត ព្រោះបារិគាត មិនគ្រប់គ្រាន់ និងដេកជាទុក្ខអស់វេលាយូរ ។ ម្យ៉ាងទៀត ពួកមនុស្ស ត្រូវចោរអង្គុលិមាលសម្លាប់អស់ប៉ុន្មាន ។ ត្រូវសម្លាប់អស់ ៩៩៩ នាក់ ហើយ ។ ក៏ចោរនោះមានសេចក្ដីសម្គាល់ថា ឥឡូវនេះ បើបានម្នាក់ទៀត ក៏នឹងគ្រប់មួយពាន់ ទើបតាំងចិត្តថា ឃើញអ្នកណាមុនក៏នឹងសម្លាប់អ្នកនោះ ឲ្យគ្រប់ចំនួន ដើម្បីធ្វើឧបចារៈដល់សិល្បៈ (ឬជាគ្រូ) គោរសេក នឹងពុក មាត់ ហើយនឹងទឹកផ្កាស់ប្ដូរសំពត់នឹងទៅជួបមាតាបិតា ដូច្នេះ ទើបចេញ ពីកណ្ដាលព្រៃមកកាន់មាត់ព្រៃ ឈរក្នុងទីម្នាង បានឃើញព្រះមានព្រះភាគ ហើយ ។ ដើម្បីនឹងសម្ដែងសេចក្ដីនេះ លោកទើបពោលថា **អទ្ទសា ខោ** ដូច្នេះជាដើម ។

[២៨៤] បទថា ***ឥទ្ធាភិសង្ខារំ អភិសង្ខារេសិ*** សេចក្ដីថា ទ្រង់បណ្ដាល ឲ្យដូចជាផែនដីធំមានរលកតាំងឡើង ហើយទ្រង់ជាន់នៅក្នុងចំណែកខាង នាយ វិលក្នុងចំណែកខាងអាយចេញទៅ ។ អង្គុលិមាល ចោលក្ដូនសារ ចេញ ហើយដើរទៅ ។ ព្រះមានព្រះភាគ ទ្រង់សម្ដែងទីទួលធំនៅខាងមុខ ហើយព្រះអង្គនៅត្រង់កណ្ដាល ចោរនៅត្រង់ចុងបំផុត ។ អង្គុលិមាលនោះ

គិតថា យើងនឹងដេញទាន់ ចាប់បានក្នុងកាលឥឡូវនេះ ទើបប្រញាប់ស្ទុះទៅដោយកម្លាំង ។

ព្រះមានព្រះភាគ ស្តេចទៅត្រង់ទីខាងចុងនៃខ្ទូល ចោរនៅត្រង់កណ្តាល គេប្រញាប់ស្ទុះមកដោយរហ័ស គិតថា ដេញទាន់នឹងចាប់បានត្រង់នេះ ។ ព្រះមានព្រះភាគ ក៏ទ្រង់បណ្តាលអណ្តូង ឬផែនដីទុកខាងមុខគេ ។ ដោយទំនងនេះ ហួតអស់ផ្លូវដល់បីយោជន៍ ។ ចោរហត់នឿយ ទឹកមាត់ក្នុងមាត់ស្ងួត ញើសហូរចេញអំពីក្លៀក ។ គ្រានេះ មានសេចក្តីគិតដូច្នេះដល់គេថា គួរអស្ចារ្យណាស់ហ្ន៎ លោកដ៏ចម្រើន ។

បទថា **មិគំបិ** សេចក្តីថា ម្រឹគដូចម្តេច នឹងបានបាន ? ។ ក្នុងពេលដែលអស់កម្លាំង ក៏ចាប់យកមកជាអាហារបាន ។ បានឮថា ចោរនោះគោះគុម្ពឈើមួយកន្លែង ឲ្យម្រឹគក្រោកឡើងគេចចេញទៅ ។ បន្ទាប់ពីនោះ ក៏នឹងជាប់តាមម្រឹគ បានដូចចិត្តប្រាថ្នាហើយអាំងស៊ី ។

[២៨៦] បទថា **ចុច្ឆយំ** សេចក្តីថា សមណៈនេះកំពុងដើរទៅពិតមែន (ក៏ថា) ឈប់ហើយ ចំណែកខ្លួនយើងឈប់ហើយ ក៏ថា មិនឈប់ ដោយហេតុណា ធ្វើដូចម្តេច ? ហ្ន៎ យើងនឹងគប្បីសួរហេតុនោះៗ ចំពោះ

សមណៈនេះ ។ បទថា **និធាយ** សេចក្តីថា សូម្បីអាជ្ញាណាដែលបុគ្គល គប្បីឲ្យប្រព្រឹត្តទៅក្នុងសត្វទាំងឡាយ ដើម្បីបៀតបៀន យើងដាក់អាជ្ញានោះ គឺ នាំចេញ ពិចារណាដោយមេត្តា ខន្តិ ប្រព្រឹត្តទៅក្នុងសាកណីយធម៌ទាំងឡាយដោយអវិហឹង្សា ។ បទថា **តុវមង្គិតោសិ** សេចក្តីថា កាលអ្នកសម្លាប់សត្វ មានប្រមាណមួយពាន់នេះ ព្រោះមិនមានសេចក្តីសង្រួមក្នុងសត្វមានជីវិតទាំងឡាយ មេត្តាក្តី ខន្តិក្តី បដិសន្ថារក្តី អវិហឹង្សាក្តី សាកណីយធម៌ក្តី របស់អ្នកទើបមិនមាន ដូច្នោះ អ្នកទើបឈ្មោះថា មិនទាន់ឈប់ ។ មានពាក្យអធិប្បាយថា សូម្បីឈប់ហើយដោយឥរិយាបថក្នុងខណៈនេះ អ្នកក៏មិនទៅកាន់ក្នុងនរក គឺ មិនគ្រាច់ទៅក្នុងកំណើតតិរច្ឆាន ក្នុងប្រេតវិស័យ ឬក្នុងអសុរកាយ ។ ក្នុងលំដាប់នោះ ចោរគិតថា ការបន្លឺសីហនាទនេះធំ ការបន្លឺដ៏ធំនេះ មិនជារបស់អ្នកដទៃមិនបាន ការបន្លឺនេះប្រាកដជារបស់ព្រះ-សមណៈព្រះនាមថា សិទ្ធត្ថៈ ជាឱរសនៃព្រះនាងមហាមាយា យើងឃើញនេះប្រាកដជាព្រះសម្មាសម្ពុទ្ធដែលមានព្រះចក្ខុមុតក្រា ទ្រង់ឃើញហើយហ្ន៎ ព្រះមានព្រះភាគស្តេចមកដើម្បីធ្វើការសង្គ្រោះដល់យើង ដូច្នេះ ទើបពោលថា **ចិរស្សំ វត មេ** ដូច្នេះជាដើម ។

ក្នុងបណ្ដាបទទាំងនោះ បទថា **មហិតោ** សេចក្ដីថា ដែលទេវតានិងមនុស្សជាដើមបូជាហើយ ដោយការបូជាដោយបច្ច័យ ៤ ។ បទថា **បច្ចុបាទិ** សេចក្ដីថា ទ្រង់ដំណើរមកកាន់ព្រៃធំនេះដើម្បីនឹងសង្គ្រោះយើង ដោយកន្លងកាលយូរណាស់ ។ ពាក្យថា **បជហិស្សំ ជាឋំ** សេចក្ដីថា ខ្ញុំព្រះអង្គនឹងលះបាប ។ បទថា **ឥទ្ធេវ** ប្រែថា ពោលយ៉ាងនេះហើយ ដោយពិត ។ បទថា **អាវុធំ** បានដល់ អាវុធ ៥ ប្រការ ។ បទថា **សោត្តេ** គឺ ដែលដាច់ទៅតែម្ខាង ។ បទថា **បបាតេ** បានដល់ ដាច់ម្ខាង ។ បទថា **នរកេ** គឺ ទីដែលបែកក្រហែង ។ ម្យ៉ាងទៀត ក្នុងទីនេះលោកពោលដល់ព្រៃប៉ុណ្ណោះ ដោយបទទាំងពីរនេះ ។ បទថា **អវកិរិ** បានដល់ ច្រោះទៅ គឺ បោលទៅហើយ ។ បទថា **គរមហិ ភិក្ខុតិ គតា អកោច** សេចក្ដីថា ព្រះមានព្រះភាគ កាលនឹងញ៉ាំងអង្គុលិមាលនេះឲ្យបួស ក៏មិនមានកិច្ចក្នុងការស្វែងរកថា នឹងបានកូនកាំបិតពីទីណា នឹងបានបាត្រចីវរពីទីណា ដូច្នេះ ។

ម្យ៉ាងទៀត ទ្រង់ពិចារណាមើលកម្ម ។ ពេលនោះទ្រង់ជ្រាបថា អង្គុលិមាលនោះ ធ្លាប់បានថ្វាយកណ្ឌៈ គឺ បរិក្ខារ ៨ ដល់លោកអ្នកមានសីលក្នុងកាលមុន ទើបទ្រង់លាព្រះហស្ដខាងស្ដាំ ត្រាស់ថា **ឯហិ ភិក្ខុ ស្វាក្ខាតោ**

**ធម្មោ ចរ ព្រហ្មចរិយំ សម្មាទុក្ខស្ស អន្តកិរិយាយ** អ្នកចូរជាភិក្ខុចុះ ធម៌គឺជាតថាគតពោលទុកល្អហើយ ចូរប្រព្រឹត្តព្រហ្មចរិយៈដើម្បីធ្វើទីបំផុតនៃទុក្ខដោយប្រពៃចុះ ដូច្នេះ ។ អង្គុលិមាលនោះ បានចំពោះនូវបាត្រ និងចីវរដែលសម្រេចដោយឫទ្ធិ ស្មើគ្នានឹងព្រះតម្រាស់នោះឯង ។ ក្នុងពេលភ្លាមនោះ ភេទគ្រហស្ថរបស់លោកអន្តរធានទៅ សមណភេទប្រាកដហើយ ។

បរិក្ខារ ៨ ដូចដែលពោលទុកយ៉ាងនេះថា ត្រៃចីវរ បាត្រ
កាំបិត ម្ជុល វត្តពន្ធចង្កេះ រួមជា ៨ នឹងសំពត់តម្រងទឹក
សមគួរដល់ភិក្ខុដែលប្រកបសេចក្តីព្យាយាមហើយ ដូច្នេះ
ជារបស់ចាំបាច់សម្រាប់ខ្លួន កើតឡើងហើយ ។

ពាក្យថា **ឯសេវ តស្ស អហុ ភិក្ខុភាវោ** សេចក្តីថា ភាពជាឯហិភិក្ខុនេះ បានជាភិក្ខុភាវៈដែលចូលដល់ព្រមដល់ព្រះអង្គុលិមាលនោះ ។ គឺថា ការឧបសម្បទផ្សេងដទៃអំពីឯហិភិក្ខុមិនមាន ក៏មិនមែន ។

បទថា **បច្ឆាសមណេន** បានដល់ បច្ឆាសមណៈអ្នកកាន់កណ្ឌៈ ។ សេចក្តីថា ព្រះមានព្រះភាគឲ្យព្រះអង្គុលិមាលកាន់បាត្រ និងចីវររបស់ខ្លួន ហើយទ្រង់ធ្វើព្រះអង្គុលិមាលនោះឲ្យជាបច្ឆាសមណៈ ស្តេចទៅហើយ ឯ

ចំណែកមាតារបស់អង្គុលិមាលនោះ មិនដឹង ព្រោះនៅឆ្ងាយគ្នាប្រមាណ ៨ អសុកៈ ដើរស្រែកហៅថា អហិង្សកៈ កូនឈរនៅទីណា កូនអង្គុយនៅទីណា កូនទៅណា ហេតុដូចម្តេចមិននិយាយនឹងម៉ែ ដូច្នេះ កាលមិនឃើញ ទើបមកដល់ទីនេះឯង ។

[២៨៧] បទថា **បញ្ចមគ្គេហិ អស្សូសេតេហិ** សេចក្តីថា បើចោរនឹងបរាជ័យ យើងនឹងជាប់តាមទៅចាប់ចោរនោះ បើយើងបរាជ័យ យើងនឹងប្រញាប់គេចចេញទៅ ដូច្នោះ ទើបចេញទៅដោយកម្លាំងសេះដ៏លឿន ។ បទថា **យេន អារាមោ** សេចក្តីថា មកកាន់ព្រះអារាមព្រោះហេតុអ្វី ។ បានឮថា ព្រះរាជានោះទ្រង់ខ្លាចចោរ មិនបានប្រាថ្នានឹងទៅ ទ្រង់ចេញទៅព្រោះក្រែងចំពោះពាក្យរិះគន់ ។ ព្រោះដូច្នោះ ព្រះអង្គទើបទ្រង់គិតរិះថា យើងនឹងថ្វាយបង្គំព្រះសម្មាសម្ពុទ្ធហើយអង្គុយ ព្រះសាស្តានឹងត្រាស់សួរថា ព្រះអង្គនាំពលចេញមកព្រោះហេតុអ្វី ដូច្នេះ ពេលនោះយើងនឹងទូលថា ក៏ព្រះមានព្រះភាគមិនបានសង្គ្រោះខ្ញុំព្រះអង្គ ដោយប្រយោជន៍ក្នុងសម្បរាយិកភពតែម្យ៉ាងប៉ុណ្ណោះ សូម្បីប្រយោជន៍ក្នុងបច្ចុប្បន្ន ក៏ទ្រង់សង្គ្រោះផង ព្រះមានព្រះភាគនឹងគិតថា បើយើងមានជ័យជំនះ ទ្រង់ក៏នឹងព្រងើយ

បើយើងបរាជ័យ ក៏ទ្រង់ត្រាស់ថា មហាបពិត្រ ប្រយោជន៍អ្វីស្ដេចមកប្រារព្ធចោរមួយនាក់ តពីនោះ មនុស្សក៏ទ្រង់យល់ផល់យើងយ៉ាងនេះថា ព្រះរាជាស្ដេចចេញចាប់ចោរ តែព្រះសម្មាសម្ពុទ្ធទ្រង់ហាមហើយ ដូច្នេះ សម្ដេចឃើញថា ទ្រង់ផុតពីពាក្យរិះគន់ដោយប្រការដូច្នេះ ទើបស្ដេចទៅហើយ ។

សួរថា ព្រះរាជាត្រាស់ថា ក៏អង្គុលិមាលចោរនោះ មកពីណា ព្រោះហេតុអ្វី ។

ឆ្លើយថា ត្រាស់ដើម្បីទ្រង់ជ្រាបពីព្រះមានព្រះភាគថា ព្រះមានព្រះ-ភាគ ទ្រង់ពិចារណាមើលឧបនិស្ស័យរបស់អង្គុលិមាលចោរនោះហើយ ទ្រង់គប្បីនាំគេមកឲ្យបួស ។ បទថា **រញ្ញោ** សេចក្ដីថា ព្រះរាជាប៉ុណ្ណោះ ទ្រង់ខ្លាចតែមួយព្រះអង្គឯង ក៏មិនមែន ។ មហាជនសូម្បីដ៏សេសក៏ខ្លាច ចោលខែល និងអាវុធ គេចចេញពីទីប្រឈមមុខនោះឯង ចូលក្រុងបិទទ្វារ ឡើងកាន់ប៉ម ឈរក្រឡេកមើល ទាំងពោលយ៉ាងនេះថា អង្គុលិមាលដឹងថា ព្រះរាជាស្ដេចមកកាន់សម្នាក់របស់យើង ដូច្នេះ ហើយមកអង្គុយចាំនៅព្រះជេតពនមុន ព្រះរាជាត្រូវអង្គុលិមាលចោរនោះចាប់ទៅហើយ តែពួកយើងគេចចេញផុតហើយ ។

[២៨៥] បទថា **ឧត្តិ តេ តរោ កយំ** សេចក្តីថា ក៏ឥឡូវនេះ អង្គុ-លិមាលនេះ មិនសម្លាប់សូម្បីស្រមោចក្រហម ភ័យអំពីសម្លាប់របស់អង្គុ-លិមាលនេះ រមែងមិនមានដល់ព្រះអង្គ ។

សួរថា លោកពោលដោយបទថា **កថំ ភោតោ** ដូច្នេះ ព្រោះហេតុអ្វី ។ ឆ្លើយថា លោកសម្គាល់ថា ការកាន់យកឈ្មោះដែលកើតឡើងព្រោះកម្មដែលគ្រោតគ្រាតហើយ ហៅបព្វជិតមិនសមគួរ យើងនឹងនឹងស្រែកហៅលោកដោយអំណាចនៃគោត្ររបស់បិតាមាតា ដូច្នេះ ទើបសួរ ។ បទថា **បរិក្ខារកំ** សេចក្តីថា យើងនឹងធ្វើការខ្វល់ខ្វាយដើម្បីប្រយោជន៍ដល់បរិក្ខារទាំងនោះ ទីនព្រះអង្គកំពុងពោលហើយនោះឯង ក៏ទ្រង់ដោះសំពត់សាដកដាក់ទុកក្នុងទីជិតជើងរបស់ព្រះថេរៈហើយ ។ ធុតង្គ ៤ ប្រការ មានការនៅក្នុងព្រៃជាវត្តជាដើម មកហើយក្នុងព្រះបាលី ។ តែព្រះថេរៈបានសមា-ទានធុតង្គទាំង ១៣ ប្រការតែម្តង ព្រោះដូច្នោះ លោកទើបពោលថា **អលំ** កុំឡើយ ដូច្នេះ ។ សួរថា លោកសំដៅដល់អ្វីទើបពោលថា **យញ្ញំ មយំ កនិតេ** ដូច្នេះ ។

ឆ្លើយថា លោកចាប់ដីជាដើមដែលព្រះករជាបញ្ជូនមកហើយក្នុងទី

ដែលមកហើយថា យើងតាមចាប់បានសូម្បីដំរីដែលរត់ យ៉ាងនេះ ។

សូម្បីព្រះរាជាក៏ទ្រង់បញ្ជូនដំរីជាដើម ជាច្រើនទៅច្រើនផង យ៉ាងនេះថា ចូរយកដំរីទៅព័ទ្ធគេ ហើយចាប់មក ចូរយកសេះទៅព័ទ្ធ ចូរយករថទៅព័ទ្ធ ហើយចាប់មក ។ កាលអ្នកទាំងនោះទៅហើយយ៉ាងនេះ កាលអង្គុលិមាល ក្រោកឡើងបញ្ចេញសំឡេងថា ហើយ! យើងជាអង្គុលិមាល សូម្បីតែម្នាក់ក៏មិនអាចលើកអាវុធបាន ។ ទឹងប្រហារមនុស្សទាំងអស់នោះសម្លាប់ចេញហើយ ។ ដំរីក៏ជាដំរីព្រៃ សេះក៏ជាសេះព្រៃ រថក៏បាក់បែក ខ្ចាត់ខ្ចាយត្រង់ទីនោះឯង ព្រះរាជាសំដៅយករឿងដូចពោលមកនេះ ទើបត្រាស់យ៉ាងនោះ ។

[២៩០] បទថា **បិណ្ឌាយ បាវិសិ** នេះ មិនមែនព្រះអង្គុលិមាលនេះចូលទៅលើកដំបូង ក៏ពាក្យនេះ លោកពោលសំដៅយកថ្ងៃដែលឃើញស្ត្រី ។ ឯព្រះអង្គុលិមាលនេះចូលទៅបិណ្ឌបាត សូម្បីរាល់ថ្ងៃ ដូចគ្នា ។ តែពួកមនុស្សឃើញលោកហើយ រមែងគក់ស្មុគខ្លះ រមែងរត់គេចទៅព្រៃទៅខ្លះ រមែងបិទទ្វារខ្លះ ។ ពួកខ្លះពេលបានឮថា អង្គុលិមាល ក៏រត់គេចចូលព្រៃខ្លះ ចូលផ្ទះបិទទ្វារខ្លះ ។ កាលមិនអាច ក៏ឈរបែរខ្នងដាក់ខ្លះ ។

ព្រះថេរៈមិនបានសូម្បីបាយយាគូត្រឹមតែមួយវែក សូម្បីភត្តត្រឹមតែមួយវែក ក៏មិនលំបាកដោយបិណ្ឌបាត ។ កាលមិនបានក្នុងខាងក្រៅ ក៏ចូលទៅកាន់ព្រះនគរ ដោយគិតថា ក្រុងនឹងទៅដល់មនុស្សគ្រប់គ្នា ។ ពេលចូលទៅផ្ទះនោះ ក៏មានហេតុដែលជាសំឡេងស្រែកចេញមកជាពាន់ៗ មានសំឡេងថា អង្គុលិមាលមកហើយៗ ។ បទថា **ឯតទហោសិ** សេចក្ដីថា បានមានហើយ ព្រោះការកើតឡើងនៃករុណា ។ កាលអង្គុលិមាលសម្លាប់មនុស្សដល់ពាន់នាក់ខ្វះមួយ (៩៩៩) ក៏មិនបាន មានសេចក្ដីករុណាត្រឹមតែម្នាក់ សូម្បីក្នុងថ្ងៃមួយ ត្រឹមតែឃើញស្ត្រីមានគភ៌វេទនាស្លាក់ហើយ សេចក្ដីករុណាកើតឡើងបានយ៉ាងណា កើតឡើងបានដោយកម្លាំងនៃបញ្ញា ។ ពិតណាស់ សេចក្ដីករុណានោះ ជាកម្លាំងនៃបញ្ញា ។

[២៩២] បទថា **តេនហិ** សេចក្ដីថា ព្រោះហេតុដែលលោកកើតសេចក្ដីករុណានោះ ។ បទថា **អរិយាយ ជាតិយា** សេចក្ដីថា ម្នាលអង្គុលិមាល អ្នកកុំកាន់យកហេតុនោះឡើយ នោះមិនមែនជាតិរបស់អ្នក នោះជាវេលាកាលនៅជាគ្រហស្ថ ធម្មតាគ្រហស្ថរមែងសម្លាប់សត្វ ។ ខ្លះរមែងធ្វើអទិន្នាទានជាដើមខ្លះ ។ តែឥឡូវនេះ ជាតិរបស់លោកឈ្មោះថា អរិយ-

ជាតិ ។ ព្រោះដូច្នោះ អ្នកកុំវៀស នឹងនិយាយយ៉ាងនេះថា **យតោ អហំ ភគិនិ ជាតោ** ព្រោះហេតុនោះឯង ទើបទ្រង់បញ្ជូនទៅ ដោយព្រះតម្រាស់ថា អ្នកចូរពោលឲ្យផ្សេងទៅយ៉ាងនេះថា **អរិយាយ ជាតិយា** ដូច្នេះ ។

ពាក្យថា **តំ ឥត្ថី ឯតទវោច** សេចក្តីថា ធម្មតាការប្រសូតបុត្ររបស់ស្ត្រីទាំងឡាយ មនុស្សប្រុសមិនគួរនឹងចូលទៅ ព្រះថេរៈធ្វើអ្វី ទើបប្រាប់ថា ព្រះអង្គុលិមាលត្ថេរមកធ្វើសច្ចកិរិយាដើម្បីប្រសូតដោយសួស្តី ។ គភ៌ិនីនោះ ជនទាំងនោះទើបបិទបាំងកំងនន តម្កល់តាំងទុកខាងក្រៅកំងនន សម្រាប់ព្រះថេរៈ ។ ព្រះថេរៈគង់លើតាំងនោះ ធ្វើសច្ចកិរិយាថា **យតោ អហំ ភគិនិ សព្វញ្ញុពុទ្ធស្ស អរិយាយ ជាតិយា ជាតោ** ម្នាលប្អូនស្រី ចាប់តាំងពីយើងកើតដោយអរិយជាតិនៃព្រះសព្វញ្ញុពុទ្ធ ។ ទារកក៏ប្រសូតមក ដូចទឹកហូរអំពីធម្មក្រក ព្រមជាមួយនឹងពាក្យសច្ចៈនោះឯង ។ ទាំងមាតាទាំងបុត្រ មានសេចក្តីសួស្តីហើយ ។ ក៏ឯព្រះបរិត្តនេះ លោកពោលទុកថា នេះឈ្មោះថា **មហាបរិត្ត** នឹងមិនមានអន្តរាយណាៗ មកទម្លាយបាន ។ ជនទាំងឡាយបានធ្វើតាំងតម្កល់ទុកត្រង់កន្លែងដែលព្រះថេរៈអង្គុយធ្វើសច្ចកិរិយា ។ ជនទាំងឡាយរមែងនាំសូម្បីសត្វតិរច្ឆានញីដែលមានគភ៌

ចាស់មកឲ្យផែកត្រង់តាំងនោះ ។ ក្នុងវេលានោះឯង ក៏ប្រសូតចេញបានដោយងាយ ។ សត្វណាទទួលនាំមកមិនបាន ក៏យកទឹកលាងតាំងនោះទៅស្រោចសីសៈ ក៏ប្រសូតចេញបានក្នុងខណៈនោះឯង ។ **សូម្បីកេតយ៉ាង ផងទឹកក៏ស្ងប់ទៅ ។ បានឮថា ព្រះមហាចារិត្តនេះ មានបាដិហារិយ៍តាំងនៅហេតុដល់អស់កប្ប** ។ សួរថា ក៏ព្រះមានព្រះភាគ រមែងឲ្យព្រះថេរៈធ្វើវេជ្ជកម្មឬ ។ ឆ្លើយថា ព្រះអង្គមិនបានឲ្យធ្វើ ។ ព្រោះពួកមនុស្សពេលឃើញព្រះថេរៈក៏ខ្លាច ហើយគេចចេញទៅ ។ ព្រះថេរៈ រមែងលំបាកដោយភិក្ខាហារ រមែងមិនអាចធ្វើសមណៈធម៌បាន ។ ទ្រង់ឲ្យធ្វើសច្ចកិរិយា ព្រោះដើម្បីសង្គ្រោះព្រះថេរៈនោះ ។ ដូចបានស្តាប់មកថា ព្រះមានព្រះភាគនោះបានមានបរិវិតក្កយ៉ាងនេះថា ឥឡូវនេះព្រះអង្គុលិមាលត្ថេរ ត្រឡប់បានមេត្តាចិត្ត ធ្វើសេចក្តីសួស្តីឲ្យដល់ពួកមនុស្សដោយសច្ចកិរិយា ដូច្នោះ ពួកមនុស្សរមែងសម្គាល់ថា គួរចូលទៅរកព្រះថេរៈ តពីនោះ ទ្រង់មិនលំបាកដោយភិក្ខាហារ អាចធ្វើសមណធម៌បាន ទើបឲ្យធ្វើសច្ចកិរិយា ព្រោះទ្រង់អនុគ្រោះដោយប្រការដូច្នេះ ។ សច្ចកិរិយា មិនមែនជាវេជ្ជកម្ម ។

ម្យ៉ាងទៀត កាលព្រះថេរៈរៀនមូលកម្មដ្ឋានដោយតាំងចិត្តថា ទ្រង់ធ្វើ

សមណធម៌ ហើយទៅអង្គុយក្នុងទីសម្រាកពេលយប់ និងទីសម្រាកពេលថ្ងៃ ចិត្តក៏នឹងមិនដំណើរឆ្ពោះទៅកាន់ព្រះកម្មដ្ឋាន ។ ក៏មិនប្រាកដចំពោះតែកន្លែងដែលលោកឈរត្រង់ព្រៃ ហើយសម្លាប់ពួកមនុស្សប៉ុណ្ណោះ ។ អាការនៃពាក្យក្តី ភាពពិការនៃដៃ និងជើងក្តី របស់អ្នកដែលខ្លាចសេចក្តីស្លាប់ថា ខ្ញុំជាអ្នកក្រខ្សត់ ខ្ញុំនៅមានបុត្រតូចៗ សូមមេត្តាឲ្យជីវិតដល់ខ្ញុំ ចុះលោកដូច្នេះ ក៏មិនមកកាន់គន្លងមាគ៌ានៃផ្លូវ៖ លោកមិនមានសេចក្តីក្តៅក្រហាយត្រូវក្រោកចេញទៅអំពីទីនោះ ។ ទីនោះ ព្រះមានព្រះភាគឲ្យធ្វើសច្ចកិរិយាដោយអរិយជាតិ ដោយទ្រង់សម្លឹងឃើញថា ព្រះអង្គុលិមាលត្រូវធ្វើជាតិនោះ ឲ្យជាអព្វោហារិក (ហិចាដ៏ក្រៃលែង) ជាមុន ហើយចម្រើនវិបស្សនាទើបនឹងសម្រេចព្រះអរហត្តបាន ។

[២៩៣] បទថា **ឯកោ វូបកដ្ឋោ** ជាដើម ពោលទុកពិស្តារហើយក្នុងវត្ថសូត្រ ។

[២៩៤] បទថា **អញ្ញេនបិ លេឌ្ឌុខិត្តោ** សេចក្តីថា ដុំដីជាដើមដែលមនុស្សបោះទៅដោយទិសាភាគណាៗ ក៏ដោយ ក្នុងទីនេះត្រឹមតែលោមព័ទ្ធទុកដោយជុំវិញ ចំពោះសត្វក្អែក សុនខ និងជ្រូកជាដើម ឲ្យត្រឡប់ទៅ

ក៏មកធ្លាក់ចុះត្រង់កាយរបស់ព្រះថេរៈនោះ ។ សំដៅយ៉ាងនេះ ក្នុងទីមានប្រមាណប៉ុនណា អន្ទាក់ដែលដាក់ហើយ ពេលលោកត្រាច់បិណ្ឌបាតត្រឡប់ហើយ ក៏ដាច់អន្ទាក់ទាល់តែបាន ។

បទថា **កិន្នុ សីសេន** សេចក្តីថា ខ្មាយស្បែករហូតដល់ឆ្អឹង ។

បទថា **ព្រាហ្មណ** លោកពោលសំដៅដល់ភាពជាព្រះខីណាស្រព ។

បទថា **យស្ស ខោត្តំ កម្មស្ស វិបាកេន** នេះ លោកពោលសំដៅយកទិដ្ឋធម្មវេទនីយកម្មដែលជាសភាគគ្នា ។ ពិតហើយ កម្មដែលលោកធ្វើនុ៎ះឯង រមែងញុំាងចំណែកទាំងបីឲ្យពេញ ក្នុងបណ្តាចិត្ត ៧ ដួង ចេតនាក្នុងជវនចិត្តដួងដំបូងជាកុសល ឬអកុសល ក៏រមែងឈ្មោះថា **ទិដ្ឋធម្មវេ-ទនីយកម្ម** ។ កម្មនោះ រមែងឲ្យវិបាកក្នុងអត្តភាពនេះប៉ុណ្ណោះ ។ កាលមិនអាច រមែងឈ្មោះថាជា **អហោសិកម្ម** ទៅ ដោយពួកបទនេះ គឺ **អហោ-សិកម្ម** (នាហោសិ **កម្មវិបាកោ**) កម្មវិបាកមិនបានមានហើយ (ន **ភវិស្សតិ កម្មវិបាកោ**) កម្មវិបាកនឹងមិនមាន (**នត្ថិ កម្មវិបាកោ**) មិនមានកម្មវិបាក ។ ជវនចេតនាដួងទី ៧ ដែលឲ្យសម្រេចប្រយោជន៍ ឈ្មោះថា **ឧបបជ្ជវេទ-នីយកម្ម** ។ កម្មនោះ រមែងឲ្យផលក្នុងអត្តភាពបន្ទាប់ទៅ ។ កាលមិនអាច

ដូច្នោះ កម្មនោះ ក៏ឈ្មោះថាជា **អហោសិកម្ម** ដោយន័យដែលពោលហើយនោះឯង ។ ជវនចេតនា ៥ ដួង ក្នុងចន្លោះកម្មទាំងពីរ រមែងឈ្មោះថា **អបរាបរិយវេទនីយកម្ម** ។ កម្មនោះ រមែងបានឱកាសកាលណា រមែងឲ្យផលកាលនោះក្នុងអនាគត ។ កាលមានការវិលវល់នៅក្នុងសង្សារ ឈ្មោះថា អហោសិកម្មរមែងមិនមាន ។ ក៏កម្មទាំង ២ នេះ របស់ព្រះថេរៈ គឺឧបបជ្ជវេទនីយកម្ម ១ អបរាបរិយវេទនីយកម្ម ១ ដែលព្រះអរហត្តមគ្គធ្វើកម្មឲ្យអស់ សម្រេចហើយ ។ នៅមានតែទិដ្ឋធម្មវេទនីយកម្ម ។ កម្មនោះសូម្បីលោកដល់ព្រះអរហត្តហើយ ក៏នៅឲ្យផលនោះឯង ។ ព្រះមាន-ព្រះភាគទ្រង់សំដៅដល់កម្មនេះ ទើបត្រាស់ថា **យស្ស ខោ ត្វំ** ជាដើម ។ ព្រោះដូច្នោះ ក្នុងពាក្យថា **យស្ស ខោ** នេះ គប្បីជ្រាបសេចក្ដីយ៉ាងនេះថា **យាទិសស្ស ខោ ត្វំ ព្រាហ្មណ កម្មស្ស វិបាកេន** ម្នាលព្រាហ្មណ៍ ដោយផលនៃកម្មឯណាប្រាកដដូចអ្នក ។

[២៩៥] បទថា **អញ្ញា មុត្តោ** នេះ ត្រឹមតែថា ជាកំពូលនៃទេសនា ។ ក្នុងទីនេះ លោកបំណងយកថា ព្រះចន្ទចេញផុតពីគ្រឿងសៅហ្មងទាំងនេះ គឺ ពពក អ័ព្ទទឹកសន្សើម ធូលី រាហូ ។ ភិក្ខុជាអ្នកផុតហើយអំពីកិលេស

គឺ សេចក្តីប្រមាទ ជាអ្នកមិនប្រមាទហើយ រមែងញ៉ាំងលោក គឺ ខន្ធ ធាតុ អាយតនៈ របស់ខ្លួននេះឲ្យភ្លឺស្វាង ថ្លើងនឹត គឺ កំលេសដែលខ្លួនកម្ចាត់ចេញហើយ ដូចជាព្រះច័ន្ទមិនមានគ្រឿងសៅហ្មង ដូចពោលមកនេះ រមែងញ៉ាំងលោកឲ្យភ្លឺស្វាង ដូច្នោះ ។ បទថា **កុសលេន បិធិយ្យតិ** សេចក្តីថា រមែងបិទដោយកុសល គឺ មគ្គ បានដល់ ធ្វើមិនឲ្យមានបដិសន្ធិទៀត ។ បទថា **យុញ្ជតិ ពុទ្ធសាសនេ** សេចក្តីថា ប្រកបហើយ ប្រកបខូទៅហើយដោយកាយ វាចា និងដោយចិត្ត នៅក្នុងព្រះពុទ្ធសាសនា ។ គាថាទាំង ៣ នេះ ហៅថា ឧទានគាថារបស់ព្រះថេរៈ ។ បានឮថា ព្រះថេរៈកាលនឹងធ្វើអាការការពារខ្លួន ទើបពោលពាក្យថា **ទិសា ហិ មេ** នេះ ។ ក្នុងបទទាំងនោះ បទថា **ទិសា ហិ មេ** សេចក្តីថា ពួកជនដែលជាសត្រូវរបស់យើងរមែងតិះដៀលយើងយ៉ាងនេះ សូម្បីព្រះអង្គុលិមាល ចូរសោយទុក្ខដូចជាពួកយើងទាំងឡាយសោយទុក្ខ ព្រោះអំណាចពួកញាតិត្រូវអង្គុលិមាលសម្លាប់ហើយ ដូច្នោះ សំដៅសេចក្តីថា ជនទាំងនោះចូរបានឮធម្មកថា គឺ សច្ចៈ ៤ របស់យើងគ្រប់ទិស ។ បទថា **យុញ្ជន្តុ** សេចក្តីថា អ្នកប្រកបហើយប្រកបខូទៅហើយដោយកាយ វាចា និងចិត្ត ។ បទថា **យេ ធម្មមេវាទប-**

**យន្តិ សន្តោ** សេចក្តីថា បុគ្គលល្អ គឺ សប្បុរសពួកណា រមែងចាប់យកធម៌នោះឯង គឺ សមាទាន គឺ កាន់យក ជនទាំងនោះ (អ្នកកើតពីមនុ) ជាសត្រូវរបស់យើង ចូរសេពគប់ ចូរសេព សំដៅសេចក្តីថា ចូរមានរូបជាទីស្រឡាញ់ចុះ ។ បទថា **អវិរោធបសំសនំ** គឺ មេត្តា លោកហៅថា **អវិរោធ** (សេចក្តីមិនក្រោធ) សំដៅសេចក្តីថា សេចក្តីមេត្តា និងសេចក្តីសរសើរ ។ បទថា **សុណន្តុ ធម្មំ កាលេន** សេចក្តីថា ចូរស្តាប់នូវធម៌ មេត្តាធម៌ បដិសន្ធារធម៌ និងសារាណីយធម៌គ្រប់ៗ ខណៈ ។ បទថា **តញ្ច អនុវិធីយន្តុ** សេចក្តីថា និងចូរធ្វើតាម គឺ បំពេញធម៌នោះឲ្យបរិបូណ៌ ។ បទថា **ន ហ ជាតុ សោ មមំហិំសេ** សេចក្តីថា បុគ្គលណាជាអ្នកប្រាថ្នាប្រទូស្តចំពោះយើង សូមបុគ្គលនោះ កុំគប្បីបៀតបៀនយើងដោយចំណែកមួយ ។ បទថា **អញ្ញំ វា បន កិញ្ចិ នំ** សេចក្តីថា ចូរកុំបៀតបៀន ចូរកុំធ្វើឲ្យលំបាកដល់យើងតែម្យ៉ាងប៉ុណ្ណោះក៏ទេ សូម្បីបុគ្គលណាៗ ដទៃក៏កុំបៀតបៀន កុំធ្វើឲ្យលំបាក ។ បទថា **បប្បុយ្យ បរមំ សន្តិំ** បានដល់ដល់ព្រះនិព្វាន ដែលមានសេចក្តីស្ងប់យ៉ាងក្រៃលែង ។ បទថា **រក្ខេយ្យ តសថាវរេ** សេចក្តីថា អ្នកនៅមានតណ្ហា លោកហៅថា អ្នកមានសេចក្តី

តក់ស្លុត អ្នកមិនមានតណ្ហា លោកហៅថា អ្នករឹងមាំ ។ លោកពោលពាក្យអធិប្បាយទុកដូច្នេះ បុគ្គលណាដល់ព្រះនិព្វាន បុគ្គលនោះរមែងជាអ្នកដែលអាចដើម្បីរក្សាសេចក្តីតក់ស្លុត និងសេចក្តីរឹងមាំទាំងអស់បាន ព្រោះដូច្នោះបុគ្គលដែលប្រាកដដូចជាយើង រមែងដល់ព្រះនិព្វាន ជនទាំងឡាយ រមែងបៀតបៀនយើងដោយចំណែកមួយមិនបានទេ ដូច្នេះ ។ លោកពោលគាថាទាំងប៉ុនេះ ដើម្បីការពារខ្លួន ។

ឥឡូវនេះ កាលនឹងសម្តែងសេចក្តីបដិបត្តិរបស់ខ្លួន ទើបពោលពាក្យមានជាដើមថា **ឧទកញ្ហិ ន យន្តិ នេត្តិកា** ។ បទថា **នេត្តិកា** ក្នុងគាថានោះសេចក្តីថា ជនពួកណា ស្អាប្រឡាយឲ្យស្អាតហើយទប់ (ទំនប់) ក្នុងទីដែលគួរទប់ ហើយបង្ហូរទឹកចូល ។

បទថា **ឧសុការា ទមយន្តិ** សេចក្តីថា (ជាងសរ) លាបដោយទឹកបាយ កែលត្រង់រងើកភ្លើង ពត់ត្រង់កន្លែងកោងធ្វើឲ្យត្រង់ ។ បទថា **តេជនំ** បានដល់ កូនសរ ។ ជាង រមែងពត់កូនសរនោះ និងឲ្យអ្នកដទៃពត់ ដូច្នោះទើបហៅថា **តេជនំ** ។ បទថា **អត្តានំ ទមយន្តិ** សេចក្តីថា បណ្ឌិតរមែងទូន្មានខ្លួន គឺ ធ្វើឲ្យត្រង់ គឺ ធ្វើឲ្យអស់អស្មិមានះ ដូចជាអ្នកបញ្ចូលទឹក

រមែងបង្ហូរទឹកទៅដោយផ្លូវត្រង់ ជាងសរក៏ធ្វើសរឲ្យត្រង់ និងជាងចាំងឈើក៏ចាំងឈើឲ្យត្រង់ ដូច្នោះ ។ បទថា **តាទិនា** សេចក្តីថា ព្រះមានព្រះភាគទ្រង់មិនញាប់ញ័រដោយអាការ ៤ ដែលមិនមានកំហុសជាប្រក្រតី ក្នុងឥដ្ឋារម្មណ៍ និងអនិដ្ឋារម្មណ៍ជាដើម គឺ ព្រះសាស្តាទ្រង់ដល់លក្ខណៈនៃការមិនញាប់ញ័រយ៉ាងនេះ ឈ្មោះថា អ្នកមិនញាប់ញ័រ ព្រោះអត្ថថា ទីងទ័ងក្នុងឥដ្ឋារម្មណ៍ និងអនិដ្ឋារម្មណ៍ ឈ្មោះថា អ្នកមិនញាប់ញ័រ ព្រោះអត្ថថា ខ្ជាក់ចេញហើយ ឈ្មោះថា អ្នកមិនញាប់ញ័រ ព្រោះអត្ថថា លះបង់ហើយ ឈ្មោះថា អ្នកមិនញាប់ញ័រ ព្រោះអត្ថថា ឆ្លងបានហើយ ឈ្មោះថា អ្នកមិនញាប់ញ័រ ព្រោះសម្តែងចេញនូវភាពនឹងមាំនោះ ។ បទថា **ភវនេត្តិ** បានដល់ ខ្សែនៃភព ។ ពាក្យនេះ ជាឈ្មោះនៃតណ្ហា ។ ពិតហើយ សត្វទាំងឡាយត្រូវតណ្ហានោះចងហទយៈទុក នាំទៅកាន់ភពនោះៗ ដូចគោដែលគេលាមទុកដោយខ្សែត្រង់ក ដូច្នោះ ព្រោះដូច្នោះ លោកទើបហៅថា **ភវនេត្តិ** (តណ្ហាដែលនាំសត្វទៅកាន់ភព) ។ បទថា **ផុដ្ឋោ កម្មវិបាកេន** សេចក្តីថា បុគ្គលដែលមគ្គចេតនាពាល់ត្រូវហើយ ។ ក៏ព្រោះកម្មដែលមគ្គចេតនាផុត គឺ ផុតនេះ ឲ្យដល់ការអស់ទៅ ដូច្នោះ មគ្គចេតនានោះ លោកទើប

ហៅថា **កម្មវិបាក** ។ ក៏ព្រះអង្គុលិមាលនេះ ដែលកម្មវិបាកនោះពាល់ត្រូវហើយ ។ បទថា **អនណោ** បានដល់ ជាអ្នកមិនមានកិលេស រមែងមិនប្រព្រឹត្តទៅដើម្បីទុក្ខវេទនា ។

ម្យ៉ាងទៀត ក្នុងពាក្យថា **អនណោ ភុញ្ជាមិ** (យើងជាអ្នកមិនជំពាក់បំណុលក្នុងការបរិភោគ) នេះ គប្បីជ្រាបការបរិភោគ ៤ យ៉ាង គឺ ថេយ្យបរិភោគ ១ ឥណបរិភោគ ១ ទាយជ្ជបរិភោគ ១ សាមិបរិភោគ ១ ។

ក្នុងបណ្តាបរិភោគ ៤ យ៉ាងនោះ ការបរិភោគរបស់អ្នកទ្រុស្តសីល ឈ្មោះថា **ថេយ្យបរិភោគ** ។ ក៏អ្នកទ្រុស្តសីលនោះ លួចបច្ច័យ ៤ បរិភោគ ។ ម្យ៉ាងទៀត ព្រះមានព្រះភាគក៏បានត្រាស់ពាក្យនេះទុកថា ម្នាលភិក្ខុទាំងឡាយ ពួកអ្នកបរិភោគដុំបាយរបស់អ្នកស្រុកដោយភាពជាចោរ ដូច្នេះ ។ ចំណែកការមិនពិចារណា ហើយបរិភោគរបស់អ្នកមានសីល ឈ្មោះថា **ឥណបរិភោគ** (បរិភោគដោយការជំពាក់បំណុល) , ការបរិភោគរបស់ព្រះសេក្ខៈ ៧ ពួកឈ្មោះថា **ទាយជ្ជបរិភោគ** (បរិភោគដោយជាទាយាទ) ។ ការបរិភោគរបស់ព្រះខីណាស្រព ឈ្មោះថា **សាមិបរិភោគ** (បរិភោគដោយភាពជាម្ចាស់របស់) ។ បទថា **មិនមានបំណុល** ក្នុងទីនេះ លោកពោលសំដៅ

យកការមិនមានបំណុល គឺ កិលេស ។ បាឋៈថា **អនិណោ** ដូច្នេះ ក៏មាន ។ បទថា **ភុញ្ជាមិ ភោជនំ** (យើងនឹងឆាន់ភោជន) លោកពោលសំដៅយកសាមិបរិភោគ ។ បទថា **កាមេតិសន្ថវំ** សេចក្តីថា អ្នកទាំងឡាយកុំប្រកបរឿយៗ គឺ កុំធ្វើសេចក្តីសរសើរដោយសេចក្តីត្រេកអរ ព្រោះតណ្ហាក្នុងកាមទាំងពីរ ។ បទថា **នយិទំ ទុម្មន្តិតំ មម** សេចក្តីថា ការដែលយើងឃើញព្រះសម្មាសម្ពុទ្ធហើយ គិតថា យើងនឹងបួស យ៉ាងណា ការគិតរបស់យើងនោះ មិនមែនជាការគិតអាក្រក់ឡើយ ។ បទថា **សុវិភត្តេសុ ធម្មេសុ** សេចក្តីថា ក្នុងធម៌ ដែលតថាគតកើតឡើងក្នុងលោកយ៉ាងនេះថា តថាគតជាសាស្តាចែកល្អហើយ ព្រះនិព្វានជាធម៌ប្រសើរបំផុត យ៉ាងណា យើងចូលដល់ហើយ ចូលដល់ព្រមហើយនូវព្រះនិព្វាននោះនោះឯង ព្រោះដូច្នោះ ការមកដល់របស់យើងនេះ ជាការមកល្អហើយ មិនប្រាសចាកប្រយោជន៍ ។ បទថា **តិស្សោ វិជ្ជា** បានដល់ បុព្វេនិវាសញ្ញាណ ទិព្វចក្ខុញ្ញាណ និងអាសវក្ខយបញ្ញា ។ បទថា **កតំ ពុទ្ធស្ស សាសនំ** សេចក្តីថា កិច្ចដែលគួរធ្វើក្នុងសាសនារបស់ព្រះពុទ្ធយ៉ាងណានៅមាន កិច្ចយ៉ាងទាំងអស់នោះ ខ្ញុំធ្វើហើយ ។ ព្រះមានព្រះភាគទ្រង់ញ៉ាំងទេសនាឲ្យដល់ទីបំផុត ដោយវិជ្ជាបី

ទំនងលោកុត្តរធម៌ ៩ ដោយប្រការផ្សេង ៗ

## " ចប់អដ្ឋកថា អង្គុលិមាលសូត្រទី ២ "

៦.អង្គុលិមាលសុត្តវណ្ណនា (ដីកាចារ្យ) (ត្រង់នេះអ្នកចេះបាលីគប្បីមើលបន្ថែម)

អង្គុលីនំ មាលំ ធារេតីតិ ឥមិនា អន្វត្ថា តស្ស សមញ្ញាតិ ទស្សេតិ។ តត្រាតិ តស្មិំ អាចរិយវ-ចនេន អង្គុលិមាលស្ស ធារណេ។ ករីសសហស្សខេត្តេ ឯកសាលិសីសំ វិយ អបញ្ញាយមានសក-កិច្ចោ ហោតីតិ អធិប្បាយោ. តក្កសីលំ បេសយិំសុ "តាទិសស្ស អាចរិយស្ស សន្តិកេ សិប្បុគ្គហ-សម្មាបយោគេន ទិដ្ឋធម្មិកេ សម្បរាយិកេ ច អត្ថេ ជានន្តោ ភារិយំ ន ករេយ្យា"តិ។ ពាហិរកា អហេ-សុំ អបរិំសកស្ស វត្តសម្បត្តិយា អាចរិយស្ស ចិត្តសភាវតោ និព្ឋត្តនតិភាវេន. សិនេហេនេវ វទន្តេតិ សិនេហេន វិយ វទន្តេ។

គណនម្បិ ន ឧគ្គណ្ហាតីតិ គណនវិធិម្បិ ន សល្លក្ខេតិ។ តត្ថ ការណមាហ "បកតិយា"តិអាទិ-នា។ ឋបិតដ្ឋានេតិ រុក្ខគច្ឆន្តរាទិកេ ឋបិតដ្ឋានេ សកុន្តសិង្ឃាលានំ វសេន អង្គុលិយោ វិនស្សន្តិ។ ភគ្គវោតិ កោសលរញ្ញោ បុរោហិតំ គោត្តេន វទតិ។ ចោរោ អវិស្សាសនីយោ សាហសិកភាវតោ។ បុរាណសន្ថតា សាខា អវិស្សាសនីយា វិច្ឆិកាទីនំ បវេសនយោគ្យត្តា។ រាជា អវិស្សាសនីយោ ឥស្សរិយមទេន ធនលោភេន ច កទាចិ ជីវិតេ សង្កាភាវតោ. ឥត្ថី អវិស្សាសនីយា លោលសីលចិត្ត-ភាវតោ។ អនុទ្ធរណីយោ ភវិស្សតិ សំសារបង្កតោ។

សង្ករិត្វាតិ "មយំ ឯកជ្ឈំ សន្និបតិត្វា ចោរំ មារេត្វា វា បលាបេត្វា គមិស្សាមា"តិ សង្ករំ កត្វា។ ឥទ្ធាភិសង្ខារន្តិ អភិសង្ខរណំ អធិដ្ឋានំ។ អភិសង្ខាសីតិ អធិដ្ឋហិ។ សំហរិត្វាតិ សំខិបិត្វា។ ឱរភាគេតិ ចោរស្ស ឱរភាគេ។

ទណ្ឌោតិ បហរណហត្ថច្ឆេទនាទិកោ ទណ្ឌនសង្ខាតោ ទណ្ឌោ។ បវត្តយិតញ្ចោតិ អានេតព្ពោ អបនេត្វាតិ អត្តនោ សន្តានតោ សមុច្ឆេទវសេន បហាយ។ បដិសង្ខាយាតិ បដិសង្ខានេន។ អវិហិំ-សាយាតិ ករុណាយ។ សារណីយធម្មេសូតិ ឆសុបិ សារណីយធម្មេសុ, ឋិតោ អដ្ឋិតានំ បាបធម្មានំ ពោធិមូលេ ឯវ សមុច្ឆិន្នត្តា។ យថា អតីតេ អបរិមិតំ កាលំ សន្ធាវិតំ, ឯវំ ឥមាយ បដិបត្តិយា អនាគ-តេបិ សន្ធាវិស្សតីតិ ទស្សេន្តោ "ឥទានី"តិអាទិមាហ។

ឥត្ថេវាតិ ឥតិ ឯវ, ឥតិ-សទ្ទោ និទស្សនត្ថោ. តេនាហ "ឯវំ វត្វា យេវា"តិ. អកិរីតិ អាកិរិ, បញ្ចបិ អាវុធានិ វិកិរិ។ តេន វុត្តំ "ខិបិ ឆឌ្ឌេសី"តិ។

ឯត្តោវាតិ អតោ ឯវ អាគតមគ្គេនេវ សាវត្ថឹ គតា។ អធិវាសេស្សតីតិ "ចោរំ បដិសេធេតុំ គមិស្សាមី"តិ វុត្តេ តុណ្ហី ភវិស្សតិ។ ទារុណកម្មេន ឧប្បន្ននាមន្តិ "អង្គុលិមាលោ"តិ ឥមំ នាមំ សន្ធាយ វទតិ។

ហត្ថី អរញ្ញហត្ថី ហោន្តិ មនុស្សានំ តត្ថ គន្តុំ អសក្កុណេយ្យត្តា, ឯវំ អស្សាបិ។ កូដសហស្សានំ ភិជ្ជនការណំ ហោតិ ថេរស្ស អាគមនភយេន យដេ ឆឌ្ឌេត្វា បលាយនេន។ គព្ភមូឡ្ហាយាតិ ព្យាកុលគព្ភាយ។ បព្វជ្ជាពលេនាតិ វុត្តំ, សត្ថុ ទេសនានុភាវេនាតិ បន វត្តព្ពំ។ សោ ហិ តស្សាបិ ការណន្តិ។ អរិយា នាម ជាតិ បព្វជ្ជា អរិយភាវត្ថាយ ជាតីតិ កត្វា។

មហាបរិត្តំ នាមេតន្តិ មហានុភាវំ បរិត្តំ នាមេតំ។ តថា ហិ នំ ថេរោ សព្ពភាវេន អរិយាយ ជាតោ សច្ចាធិដ្ឋានេន អកាសិ។ តេនាហ "សច្ចកិរិយកតដ្ឋានេ"តិ។ គព្ភមូឡ្ហន្តិ មូឡ្ហគព្ភំ។ គព្ភោ ហិ បរិបក្កោ សម្បជ្ជមានោ វិជាយនកាលេ កម្មជវាតេហិ សញ្ចាលេត្វា បរិវត្តិតោ ឧទ្ធំបាទោ អធោសីសោ ហុត្វា យោនិមុខាភិមុខោ ហោតិ, ឯវំ សោ កស្សចិ អលគ្គោ សោត្ថិនា ពហិ និក្ខមតិ, វិបជ្ជមានោ បន វិបរិវត្តនវសេន យោនិមគ្គំ បិទហិត្វា តិរិយំ និបជ្ជតិ, តថា យស្សា យោនិមគ្គោ បិទហតិ, សា តត្ថ កម្មជវាតេហិ អបរាបរំ បរិវត្តមានា ព្យាកុលា មូឡ្ហគព្ភាតិ វុច្ចតិ, តំ សន្ធាយ វុត្តំ "គព្ភមូឡ្ហ"ន្តិ។

សច្ចកិរិយា នាម ពុទ្ធាសយំ អត្តនោ សីលំ បច្ចវេក្ខិត្វា កតា, តស្មា សច្ចកិរិយា វេជ្ជកម្មំ ន ហោតីតិ ទដ្ឋព្វំ។ ថេរស្សបិ ចាតិអាទិនា ឧបសង្កមិតព្វការណំ វទតិ។ ឥមេ ទ្វេ ហេតូ បដិច្ច ភគវា ថេរំ សច្ចកិរិយំ ការេសិ។ ជាតិន្តិ មូលជាតិំ។

បរិយាទាយ អាហច្ច ភិន្នេន សីសេន។ សភាគទិដ្ឋធម្មវេទនីយកម្មន្តិ និរយេ និព្វត្តនសកកម្មសភាគភូតំ ទិដ្ឋធម្មវេទនីយកម្មំ. សភាគតា ច សមានវត្ថុកតា សមានារម្មណតាឯកវីថិបរិយាបន្នតាទិវសេន សព្វថា សរិក្ខតា, សទិសម្បិ ច នាម តទេវាហរីយតិ យថា "តស្សេវ កម្មស្ស វិបាកោ"តិ ច "សា ឯវ តិត្តិរី តានេវ ឱសធានី"តិ ច។ ឥទានិ តមេវ សភាគតំ ទស្សេតុំ "កម្មំ ហី"តិអាទិ អារទ្ធំ។ ករិយមានមេវាតិ បច្ចយសមវាយេន បដិបាដិយា និព្វត្តិយមានមេវ។ តយោ កោដ្ឋាសេ បូរេតិ, ទិដ្ឋធម្មវេទនីយអបរាបរិយាយវេទនីយឧបបជ្ជវេទនីយសង្ខាតេ តយោ ភាគេ បូរេតិ, តេសំ តិណ្ណំ ភាគានំ វសេន បវត្តតិ។

ទិដ្ឋធម្មោ វុច្ចតិ បច្ចក្ខភូតោ បច្ចុប្បន្នោ អត្តភាវោ, តត្ថ វេទិតព្ពផលំ កម្មំ ទិដ្ឋធម្មវេទនីយំ។ បច្ចុប្បន្នភវតោ អនន្តរំ វេទិតព្វផលំ កម្មំ ឧបបជ្ជវេទនីយំ។ ទិដ្ឋធម្មានន្តរភវតោ អញ្ញស្មឹ អត្តភាវបរិ-

យាយេ អត្តភាវបរិវត្តេ វេទិតព្ពផលំ កម្មំ អបរាបរិយាយវេទនីយំ។ បដិបក្ខេហិ អនភិភូតតាយ, បច្ចយវិសេសេន បដិលទ្ធវិសេសតាយ ច ពលវភាវប្បត្តា តាទិសស្ស បុព្វាភិសង្ខារស្ស វសេន សាតិសយា ហុត្វា បវត្តា បឋមជវនចេតនា តស្មិំយេវ អត្តភាវេ ផលទាយិនី ទិដ្ឋធម្មវេទនីយា នាម។ សា ហិ វុត្តាការេន ពលវតិ ជវនសន្តានេ គុណវិសេសយុត្តេសុ ឧបការានុបការវសប្បវត្តិយា អាសេវនាលាភេន អប្បវិបាកតាយ ច ឥតរទ្វយំ វិយ បវត្តសន្តានុបរមាបេក្ខំ ឱកាសលាភាបេក្ខញ្ច កម្មំ ន ហោតីតិ ឥធេវ បុប្ផមត្តំ វិយ បវត្តិវិបាកមត្តំ ផលំ ទេតិ។

តថា អសក្កោន្តន្តិ កម្មស្ស ផលទានំ នាម ឧបធិបយោគាទិបច្ចយន្តរសមវាយេនេវ ហោតីតិ តទភាវតោ តស្មិំយេវ អត្តភាវេ វិបាកំ ទាតុំ អសក្កោន្តំ។ អហោសិកម្មន្តិ កម្មំយេវ អហោសិ, ន តស្ស វិបាកោ អហោសិ, អត្ថិ ភវិស្សតិ វាតិ ឯវំ វត្តព្វំ កម្មំ។ អត្ថសាធិកាតិ ទានាទិបាណាតិបាតាទិអត្ថស្ស និប្ផាទិកា។ កា បន សាតិ អាហ "សត្តមជវនចេតនា"តិ។ សា ហិ សន្និដ្ឋាបកចេតនា វុត្តនយេន បដិលទ្ធវិសេសា បុរិមជវនចេតនាហិ លទ្ធាសេវនា ច សមានា អនន្តរេ អត្តភាវេ វិបាកទាយិនី ឧបបជ្ជវេទនីយកម្មំ នាម។ តេនាហ "អនន្តរេ អត្តភាវេ វិបាកំ ទេតី"តិ។ សតិ សំសារប្បវត្តិយាតិ ឥមិនា អសតិ សំសារប្បវត្តិយា អហោសិកម្មបក្ខេ តិដ្ឋតិ វិបច្ចនោកាសស្ស អភាវតោតិ។

សមុគ្ឃាដិតានិ វិបច្ចនោកាសស្ស អនុប្បត្តិធម្មតាបាទនេន។ ទិដ្ឋធម្មវេទនីយំ អត្ថិ វិបាការហាភាវស្ស អនិព្វត្តិតត្តា វិបច្ចនោកាសស្ស អនុបច្ឆិន្នត្តា។ កតូបចិតញ្ហិ កម្មំ សតិ វិបច្ចនោកាសេ យាវ ន ផលំ ទេតិ, តាវ អត្ថេវ នាម វិបាការហភាវតោ។ "យស្ស ខោ"តិ ឥទំ អនិយមាការវចនំ ភគវតា កម្មសរិក្ខតាវសេន សាធារណតោ វុត្តន្តិ អាហ "យាទិសស្ស ខោ"តិ។

បមាទកិលេសវិមុត្តោតិ បមាទហេតុកេហិ សព្វេហិ កិលេសេហិ វិមុត្តោ។

បាបស្ស បិធានំ នាម អវិបាកធម្មតាបាទនន្តិ អាហ "អប្បដិសន្ធិកំ ករីយតី"តិ។ ពុទ្ធសាសនេតិ សិក្ខាត្តយសង្គហេ ពុទ្ធស្ស ភគវតោ សាសនេ។ យុត្តប្បយុត្តោ វិហរតីតិ អកត្តព្ពស្ស អករណវសេន, កត្តព្ពស្ស ច បរិបូរណវសេន បវត្តតិ។

ទិស្សន្តិ កុជ្ឈន្តីតិ ទិសា, បដិបក្ខាតិ អាហ "សបត្តា"តិ។ តប្បសំសបការន្តិ មេត្តានិសំសកិត្តនាការំ។ កាលេនាតិ អាមេឌិតលោបេន និទ្ទេសោតិ អាហ "ខណេ ខណេ"តិ។ អនុករោន្តូតិ យេសំ កល្យាណមិត្តានំ សន្តិកេ សុណន្តិ, យថាសុតំ ធម្មំ តេសំ អនុករោន្តុ ទិដ្ឋានុគតិករណំ អាបជ្ជន្តុ, អត្តនោ វេរិបុគ្គលានម្បិ ភគវតោ សន្តិកេ ធម្មស្សវនំ សម្មាបដិបត្តិញ្ច បច្ចាសីសតិ។

តសន្តិ គតិំ បត្ថយន្តីតិ តសា ភវន្តរាទីសុ សំសរណភាវតោ។ តេនាហ "តសា វុច្ចន្តិ សតណ្ហា"តិ។

នេតព្ពដ្ឋានំ ឧទកំ នយន្តីតិ នេត្តិកា។ ពន្ធិត្វាតិ ទឡ្ហំ ពន្ធិត្វា។ តេលកញ្ជិកេនាតិ តេលមិស្សិតេន កញ្ជិកេន។

យាទិសោវ អនិដ្ឋេ, តាទិសោវ ឥដ្ឋេតិ ឥដ្ឋានិដ្ឋេ និព្វិការេន តាទី។ យេសំ បន កាមាមិសាទីនំ វន្តត្តា រាគាទីនំ ចត្តត្តា កាមោឃាទីនំ តិណ្ណត្តា តាទិភាវោ ភវេយ្យ, តេសំ ភគវតា សព្វសោ វន្តា ចត្តា តិណ្ណា, តស្មា ភគវា វន្តាវីតិ តាទី, ចត្តាវីតិ តាទី, តិណ្ណាវីតិ តាទី, យេហិ អនញ្ញសាធារណេហិ សីលាទិគុណេហិ សមន្នាគតត្តា ភគវា តាទិភាវេន ឧក្កំសបារមិប្បត្តោ តំនិទ្ទេសោ, តេហិ គុណេហិ យាថាវតោ និទ្ទិសិតព្ពតោបិ តាទី។ យថា យន្តរជ្ជុយា យន្តំ នីយតិ, ឯវំ យាយ តណ្ហាយ ភវោ នីយតិ, សា "ភវនេត្តិ ភវរជ្ជូ"តិ វុត្តា។ តេនាហ "តាយ ហី"តិអាទិ, កម្មានិ កុសលាទីនិ វិបច្ចយន្តិ អបច្ចយន្តិ ឯតាយាតិ កម្មវិបាកោ។ អបច្ចយភាវោ នាម អរិយមគ្គចេតនាយាតិ អាហ "មគ្គចេតនាយា"តិ។ យាវ ន កិលេសា បហីយន្តិ, តាវ ឥមេ សត្តា សឥណា ឯវ អសេរីវិហារភាវតោតិ អាហ "អណណោ និក្កិលេសោ ជាតោ"តិ។

ថេយ្យបរិភោគោ នាម សាមិបរិភោគាភាវតោ។ ភគវតាបិ ហិ អត្តនោ សាសនេ សីលវតោ បច្ចយា អនុញ្ញាតា, ន ទុស្សីលស្ស, ទាយកានំ សីលវតោយេវ បរិច្ចាគោ, ន ទុស្សីលស្ស អត្តនោ ការានំ មហប្ផលភាវស្ស បច្ចាសីសនតោ។ ឥតិ សត្ថារា អននុញ្ញាតត្តា ទាយកេហិ ច អបរិច្ចត្តត្តា "ទុស្សីលស្ស បរិភោគោ ថេយ្យបរិភោគោ នាមា"តិ វុត្តំ ។ ឥណវសេន បរិភោគោ ឥណបរិភោគោ។ បដិគ្គាហកតោ ទក្ខិណាវិសុទ្ធិយា អភាវតោ ឥណំ គហេត្វា បរិភោគោ វិយាតិ អត្ថោ។ យស្មា សេក្ខា ភគវតោ ឱរសបុត្តា, តស្មា តេ បិតុសន្តកានំ បច្ចយានំ ទាយាទា ហុត្វា តេ បច្ចយេ បរិភុញ្ជន្តីតិ តេសំ បរិភោគោ ទាយជ្ជបរិភោគោ នាម។ កិំ បន តេ ភគវតោ បច្ចយេ បរិភុញ្ជន្តិ, ឧទាហុ គិហីហិ ទិន្នន្តិ? គិហីហិ ទិន្នាបិ តេ ភគវតា អនុញ្ញាតត្តា ភគវតោ សន្តកា ហោន្តិ អននុញ្ញាតេសុ សព្ពេន សព្ពំ បរិភោគាភាវតោ អនុញ្ញាតេសុយេវ បរិភោគសម្ភវតោ។ ធម្មទាយាទសុត្តញ្ចេត្ថ សាធកំ។

អវីតរាគានំ តណ្ហាបរវសតាយ បច្ចយបរិភោគេ សាមិភាវោ នត្ថិ, តទភាវេន វីតរាគានំ តត្ថ សាមិភា-វោ យថារុចិ បរិភោគសម្ភវតោ។ តថា ហិ តេ បដិកូលម្បិ អប្បដិកូលាការេន, អប្បដិកូលម្បិ បដិកូ-លាការេន តទុភយំ វិវជ្ជេត្វា ឧបេក្ខាការេន ច បច្ចយេ បរិភុញ្ជន្តិ, ទាយកានញ្ច មនោរថំ បរិបូរេន្តិ។ សេសមេត្ថ យំ វត្តព្វំ, តំ វិសុទ្ធិមគ្គេ, តំសំវណ្ណនាសុ ច វុត្តនយេនេវ វេទិតព្វំ។ កិលេសឥណានំ អភាវំ

សន្ទាយ "អណោណោ"តិ វុត្តំ, ន បច្ចវេក្ខិតបរិភោគមត្តំ។ តេនាហ អាយស្មា ច ពាកុលោ "សត្តាហមេវ ខោ អហំ, អាវុសោ, សរណោ រដ្ឋបិណ្ឌំ ភុញ្ជិ"ន្តិ ។

វត្ថុកាមកិលេសកាមេហិ តណ្ហាយ បវត្តិអាការំ បដិច្ច អត្ថិ រមណវោហារោតិ អាហ "ទុវិធេសុបិ កាមេសុ តណ្ហារតិសន្ថវ"ន្តិ។ មន្ទិតន្តិ កថិតំ។ ឧប្បន្នេហិ សត្ថុបដិញ្ញេហិ។ សំវិភត្តាតិ កុសលាទិវ-សេន ខន្ធាទីហិ អាការេហិ វិភត្តា។ សុន្ទរំ អាគមនន្តិ ស្វាគតំ។ តតោ ឯវ ន កុច្ឆិតំ អាគតំ។ សោឡ-សវិធកិច្ចស្ស បរិយោសិតត្តា អាហ "តំ សព្វំ មយា កត"ន្តិ។ មគ្គបញ្ញាយមេវ តតិយវិជ្ជាសមញ្ញាតិ អាហ "តីហិ វិជ្ជាហិ នវហិ ច លោកុត្តរធម្មេហី"តិ។

អង្គុលិមាលសុត្តវណ្ណនាយ លីនត្ថប្បកាសនា សមត្តា។